00777431



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 09-Feb-2012, 12:02

CMS/CFO: Kauv Keoratanak

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# <u>ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី២៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់

*(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក មៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ស៊ីន សុវ៉ន

លោក វ៉េន ពៅ

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅជនជាប់ចោទ នួន ជា

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី៖...............................................................ទំព័រ ០៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅព្រឹកនេះ តាមកាលបរិច្ឆេទដែលបានគ្រោងទុក គឺអង្គជំនុំជម្រះបន្តស្តាប់ចម្លើយរបស់ជនជាប់ចោទ នួន ជា ដែលនឹងត្រូវសួរដោយក្រុមមេធាវីការពារក្តីរបស់គាត់។

អនុរក្សមន្ទីរឃុំឃាំងឲ្យជនជាប់ចោទ នួន ជា មកកាន់ឈើរាងវង់ក្រចកសេះ នៅពីមុខអង្គជំនុំជម្រះនេះ ។

សូមអញ្ជើញលោក អាង ឧត្តម!

**លោក អាង ឧត្តម៖**

សូមគោរព លោកប្រធាន។ សូមគោរព លោក លោកស្រីចៅក្រម។ សូមអភ័យទោស ដែលថាខ្ញុំនឹងធ្វើសំណើ មិនប្រក្រតីខុសពីលើកកមុនៗ ហើយលោក អៀង សារី នៅពេលនេះ ស្នើសុំលះបង់សិទ្ធិមិនចូលរួមសវនាការដោយផ្ទាល់ទេ ប៉ុន្តែសូមចូលរួមសវនាការដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម ដោយមូលហេតុ សុខភាព ក្រៅពីការឈឺឆ្អឹងខ្នងខ្លាំង ឥឡូវគាត់មានបញ្ហាហើមជើង ហើយខ្ញុំបានពិគ្រោះយោបល់ជាមួយលោកគ្រូពេទ្យប្រចាំនៅទីនេះ ថាគួរតែសុំអនុញ្ញាត ឲ្យលោកប្រធានមេត្តាអនុញ្ញាតឲ្យគាត់ចូលរួមសវនាការនៅបន្ទប់ខាងក្រោម ដើម្បីឲ្យគាត់បានសម្រួល បានលើកជើងតាមតែពេទ្យណែនាំ។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាឲ្យគាត់បានចូលរួមសវនាការនៅបន្ទប់ជាន់ខាងក្រោមសម្រាប់ថ្ងៃនេះ តែម្តង។ សូមលោកប្រធានមេត្តាអនុញ្ញាត។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៤:២៤]

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តី

របស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការដោយផ្ទាល់ ដោយសុំដកខ្លួនថយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមបន្ទប់នៅខាងក្រោមដែលមានតភ្ជាប់នូវប្រព័ន្ធសោតទស្សន៍។ ដោយមូលហេតុបញ្ហាសុខភាព មិនអាចអង្គុយយូរបាន។

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ ដោយសុំលះបង់សិទ្ធិក្នុងការចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ហើយដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមសាលសវនាការនេះដែលមាន-- តាមរយៈឧបករណ៍សោតទស្សន៍។

[០៩:០៥:២១]

មេធាវី អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីប្រគល់មកអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់របស់ជនជាប់ចោទ ដោយមានចុះហត្ថលេខា ឬស្នាមផ្តិត-- ផ្តិតស្នាមម្រាមដៃជាក់ច្បាស់របស់ជនជាប់ចោទផង ហើយបង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សំឡេង និងរូបភាព សម្រាប់ជនជាប់ចោទអាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលដំណើរការសវនាការសម្រាប់ថ្ងៃនេះតែម្តង។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនលោក អៀង សារី ត្រឡប់ទៅកាន់បន្ទប់ខាងក្រោម បន្ទប់សវនាការនេះ ដែលបានរៀបចំទុកនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់។ នាំទៅចុះ!

[០៩:០៦:១៧]

មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសនៅក្នុងការសួរសំណួរជំនួសកូនក្តីរបស់ខ្លួន ពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រកម្ពុជា។ អង្គជំនុំជម្រះសូមសួរទៅក្រុមមេធាវីការពារក្តី នួន ជា ថាតើលោកត្រូវការពេលវេលាប្រហែលប៉ុន្មានដែរ នៅក្នុងការសួរដេញដោលចំពោះកូនក្តីរបស់លោក នៅក្នុងកម្រិតព្រំដែននៃវិសាលភាព និងអង្គហេតុបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជានេះ?

**លោក ម៉ៃខល ផេសមិន៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រមទាំងអស់ ហើយនិងសវនាការ ហើយខ្ញុំជឿថា យើងជាភាគីចុងក្រោយដែលត្រូវសួរទៅកូនក្តីរបស់យើងនៅក្នុងបរិបទនេះ។ ខ្ញុំមិនមានសំណួរច្រើនប៉ុន្មានទេ គឺមានតែបី ឬបួនប៉ុណ្ណោះ។ ប៉ុន្តែខ្ញុំមានការលំបាកក្នុងការសួរសំណួរ ដោយហេតុថា

គាត់នឹងឆ្លើយវែង ប៉ុន្តែតាមធម្មតាប្រហែលជាមិនលើសពី៣០នាទីទេ បាទ។ ខ្ញុំមានសំណួរខ្លីៗពីរ-- មានបញ្ហានីតិវិធីខ្លីៗដែលខ្ញុំចង់ជម្រាបជូនតុលាការ មុននឹងខ្ញុំចាប់ផ្ដើមសំណួរ ឬក៏បន្ទាប់ពីសួរសំណួរ។

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអីទៅ? ពាក់ព័ន្ធនឹងនីតិវិធីនៃការសួរដេញដោលប៉ុណ្ណោះ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើសេចក្ដីថ្លែងការណ៍អ្វីផ្សេងៗទេនៅក្នុងអំឡុងពេលនេះ។

[០៩:០៨:២១]

**លោក ម៉ៃខល ផេសមិន៖**

អរគុណលោកប្រធាន។ ជាបឋម ទាក់ទងទៅនឹងសាក្សីដែលបានផ្ដល់សក្ខីកម្មមកហើយនោះ។ ទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រនៃរឿងក្ដីនេះ យើងខ្ញុំគិតថាសាក្សីដែលយើងបានស្ដាប់នោះ គឺមិនអាចផ្ដល់សក្ខីកម្មទាំងស្រុងអំពីប្រវត្តិសាស្ត្រនោះបានទេ។ ដូចជាតាមរយៈការផ្ដល់សក្ខីកម្មតាមវីដេអូ *ខនហ្វឺរិន* ដែលយើងបានធ្វើកាលពីកន្លងមកនោះ ទាក់ទងទៅនឹងសម័យកាលមុនឆ្នាំ១៩៧៥នោះ ហើយឯកសារមួយចំនួនលើកឡើងមកដេញដោល ហើយយើងបានប្រកាសជូនតុលាការថា នឹងត្រូវស្ដាប់សាក្សីមួយចំនួនទៀតទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ទោះជាក្នុងករណីណាក៏ដោយ យើងសន្និដ្ឋានថា តុលាការនឹងអនុញ្ញាតឲ្យយើងសួរសាក្សីផ្សេងទៀតនៅក្នុងដំណាក់ក្រោយនៃសវនាការ ជាពិសេសរួមទាំងអ្នកជំនាញផងដែរទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រដូចជាប្រធានបទពិសេស ទោះបីជាសាក្សីទាំងអស់នេះមិនត្រូវបានកោះហៅ ឬក៏បានតុលាការស្នើឲ្យផ្ដល់សក្ខីកម្មក៏ដោយ យើងនៅតែទាមទារឲ្យមានការបំភ្លឺបែបនោះ។

ចំណុចទីពីរ ដែលខ្ញុំចង់ជម្រាបតុលាការនោះ ខ្ញុំពិនិត្យឃើញថា អាចធ្វើឲ្យលោកចៅក្រមមិនសូវសប្បាយចិត្ត ក៏ប៉ុន្តែខ្ញុំនឹង-- ហើយខ្ញុំមិនត្រូវបានតុលាការពេញចិត្តប៉ុន្មានទេ ដែលខ្ញុំលើកឡើងបញ្ហានោះម្ដងហើយម្ដងទៀត។ ដោយភាពស្មាក់ស្មើរមួយចំនួននោះ គឺថាយើងត្រូវពិនិត្យឡើងវិញនៅក្នុងការកត់សម្គាល់ដែលធ្វើឡើងដោយនៅសន្និសីទកាសែតនៅប្រទេសវៀតណាមក្នុងពេលកន្លងមក--

[០៩:១០:២៣]

**ប្រធានអង្គជំនុំ៖**

យើងដូចជាបានប្រាប់អ្នកឯងរួចហើយ ថាអ្នកឯងមិនអាចធ្វើឆ្លៀតឱកាសនៅក្នុងការដែលយើងផ្ដល់ពេលវេលាឲ្យអ្នកឯងសួរទៅកូនក្ដីរបស់អ្នកឯង ពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រទៅលើបញ្ហាផ្សេង

ទៀតទេ។ ផ្សេងនោះអង្គជំនុំជម្រះបានឆ្លើយតបរួចហើយ អ្វីដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ ប្រសិនបើអ្នកឯងមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ អ្នកឯងអាចប្តឹងសាទុក្ខទៅតាមនីតិវិធីតុលាការ។ យើងដាច់ខាតមិនឲ្យអ្នកឯងធ្វើអ្វីទៅតាមតែការនឹកឃើញរបស់អ្នកឯងបានទៀតឡើយ។

ឥឡូវនេះយើងផ្តល់ឲ្យអ្នកឯងសួរសំណួរពាក់ព័ន្ធជាមួយនឹងបរិបទប្រវត្តិសាស្ត្រ ចំពោះកូនក្តីរបស់អ្នកឯងចាប់ពីពេលនេះតទៅ។ បើមិនសួរទេ គឺអាចចាត់ទុកថាអ្នកឯងលះបង់សិទ្ធិក្នុងការសួរដេញដោលចំពោះសាក្សីពាក់ព័ន្ធទៅនឹងអង្គហេតុប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជានេះហើយ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំពិតជាមានសំណួរមែនបាទ។ ហើយយើងនឹងសូមប្រកាសថា សេចក្តីសម្រេចទាំងអស់នោះ និងពេលនេះយើងនឹងធ្វើការប្តឹងឧទ្ធរណ៍នៅពេលណាមួយ ឬនៅពេលមានសាលក្រមក្នុងករណីលើករណីនេះ។ ខ្ញុំសូមអនុញ្ញាតពន្យល់ដោយសង្ខេបថា យើងប្រកាន់នូវជំហរថា សេចក្តីសម្រេចរបស់លោកចៅក្រម គឺថា--

[០៩:១២:២០]

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យអ្នកឯងធ្វើសេចក្តីថ្លែងការណ៍អីផ្សេងទេ។ ឥឡូវនេះបើអ្នកឯងមិនប្រើសិទ្ធិក្នុងការសួរទេ គឺយើងនឹងប្តូរកម្មវិធី ដើម្បីចាត់នីតិវិធីជាបន្ត ដោយកម្មវិធីនៃការបរិច្ឆេទរបស់អង្គជំនុំជម្រះត្រូវបន្តធ្វើដោយតាមលំដាប់លំដោយនៃកិច្ចដំណើរការជាហូរហែទៀត ដើម្បីជំរុញពន្លឿនកិច្ចដំណើរការសវនាការរឿងក្តីនេះឲ្យបានឆាប់រហ័ស និងយុត្តិធម៌តាមដែលអាចខិតខំធ្វើទៅបាន។

**លោក ម៉ៃខល ផេសមិន៖**

ប៉ុន្តែខ្ញុំ យ៉ាងហោចណាស់ តុលាការគប្បីតែអនុញ្ញាតឲ្យខ្ញុំពន្យល់ពីមូលហេតុថា ហេតុអ្វីបានខ្ញុំលើកបញ្ហានេះ?--

[០៩:១៣:០៥]

**ប្រធានអង្គជំនុំ៖**

យើងបានឆ្លើយរួចហើយ អត់មានត្រូវការស្តាប់អីទៀតទេ។ អង្គជំនុំជម្រះមិនស្តាប់ពាក់ព័ន្ធនឹងបញ្ហាអ្វីដែលអង្គជំនុំជម្រះបានសម្រេចរួចហើយទេ។

**លោក ម៉ៃខល ផេសមិន៖**

តើខ្ញុំយល់ថា តើខ្ញុំត្រូវបានទទួលការបង្ខំឲ្យដាក់ពាក្យបណ្ដឹងនៅពេលនេះដែរឬទេ បើតាមពិនិត្យទៅនោះបាទ?

**ប្រធានអង្គជំនុំ៖**

យើងមិនបង្ខំអ្នកឯងរឿងការដាក់ពាក្យបណ្ដឹងទេ នេះជាសិទ្ធិរបស់លោកក្នុងនាមលោកជាមេធាវីការពារក្ដី។ លោកមើលបទប្បញ្ញត្តិដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនៅក្នុងការប្រើប្រាស់នៅ អ.វ.ត.ក នេះ ហើយអនុវត្តសិទ្ធិរបស់លោកទៅតាមនោះទៅ។ អង្គជំនុំជម្រះបានកំណត់នូវកាលវិភាគនៅក្នុងបញ្ហាបរិបទនីមួយៗ សម្រាប់ធ្វើសវនាការដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី។ ហើយយើងបានប្រាប់ច្បាស់លាស់ណាស់ មុននឹងផ្ដល់វេទិកាឲ្យលោកសួរទៅដល់កូនក្ដីរបស់លោក គឺបានប្រាប់ថា ពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ដែលយើងបានកំណត់ធ្វើសវនាការសម្រាប់វគ្គមួយនៃអង្គហេតុសវនាការដំណាក់កាលដំបូង នៃកិច្ចដំណើរការសវនាការដែលយើងប្រើប្រាស់ពាក្យមួយទៀតថា សំណុំរឿង០០២/០១។

ក្រៅពីនេះយើងមិនអនុញ្ញាតទេ ហើយការអនុញ្ញាតគឺមានកម្រិតត្រឹមតែដេញដោលនៅក្នុងអង្គហេតុដែលកំណត់ឲ្យធ្វើសវនាការប៉ុណ្ណោះ។

[០៩:១៥:០៧]

**លោក ម៉ៃខល ផេសមិន៖**

យើងខ្ញុំទទួលតាមពាក្យនូវកម្មវិធីដែលតុលាការបានសម្រេចនោះហើយ ក៏ប៉ុន្តែយើងនៅតែប្រកាន់ជំហរថា យើងនឹងត្រូវមានសំណួរមួយចំនួន ហើយនិងដាក់សំណើមួយចំនួនបន្ទាប់ទៅទៀត។ ហើយយើងមានពេលគ្រប់គ្រាន់នៅសប្ដាហ៍ក្រោយ ដើម្បីនឹងដាក់ពាក្យសំណើ ឬក៏បញ្ហាទាក់ទងទៅនឹងបញ្ហានេះ។ ខ្ញុំនឹងពន្យល់នៅពេលនោះ ប៉ុន្តែនៅពេលនេះខ្ញុំមិនទាន់បញ្ជាក់ពីបញ្ហានោះទេ។ ដូច្នេះថាតើឲ្យតុលាការជម្រាបខ្ញុំផងថា ពេលណាខ្ញុំអាចលើកបញ្ហានោះបាន ប្រសិនជាអាច។ សំណួរ!

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៦:៤៦]

**ប្រធានអង្គជំនុំ៖**

សិទ្ធិរបស់លោកក្នុងការដាក់កន្លងមកដូចជា លោកមិនដែលបានសួរអង្គជំនុំជម្រះមុនទេ លោក

ដាក់ពាក្យសំណើសុំផ្សេងៗ ដូចលោកមិនដែលបានសួរសំណួរនេះមុនថា តើលោកគួរដាក់ៗយ៉ាងម៉េច? ដាក់នៅពេលណា? ដូចជាលោកមិនដែលបានសួរទេ។ ទីពីរ អង្គជំនុំជម្រះនឹងផ្តល់វេទិកាទៅលោក ដប់ប្រាំនាទីទៀតនៅក្នុងការសួរទៅកូនក្តីរបស់លោក។ ហើយប្រសិនបើលោកចាក-- ប្រាសចាកនឹងការកំណត់នេះ គឺលោកនឹងបាត់បង់សិទ្ធិនៅក្នុងការទទួលនូវពេលវេលាដែលត្រូវមានឱកាសក្នុងការសួរដេញដោលកូនក្តីរបស់លោកហើយ។

**លោក ម៉ៃខល ផេសមិន៖**

បាទ ខ្ញុំ-- តាមពិតខ្ញុំមិនអាចទទួលចម្លើយលោកប្រធាននោះបានទេ ខ្ញុំចង់បានថា តើពេលណាដែលខ្ញុំអាចលើកបញ្ហានីតិវិធីដូចដែលខ្ញុំលើកខាងដើមនេះបានបាទ។ លុះត្រាតែខ្ញុំបានចម្លើយនោះ ទើបបានខ្ញុំអាចតទៅមុខបាន។

[០៩:១៧:៥៧]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៨:១៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីរូបនេះមានឥរិយាបថមិនគោរពដល់អង្គជំនុំជម្រះឡើយ ហើយគាត់បានបង្ហាញឥរិយាបថមិនប្រើប្រាស់ពេលវេលានៅក្នុងការសួរកូនក្តីរបស់លោកទេ។ ដូច្នេះបើលោកអស់ពេលហើយ សូមអង្គុយចុះ!

បាទ សូម-- បើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីសួរទៅជនជាប់ចោទដែរឬទេ? ថែមទៀតទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំមានសំណួរមួយចំនួនចោទសួរទៅលោក នួន ជា ដែលពាក់ព័ន្ធទៅនឹងអ្វីដែលបានលើកឡើងក្នុងការដេញដោលនេះ។

បាទ ខ្ញុំមានសំណួរមួយទាក់ទងទៅនឹងអ្វីដែលជនជាប់ចោទបានលើកឡើងទាក់ទងទៅនឹងការបំបាត់រូបិយប័ណ្ណនៅក្នុងតំបន់រំដោះចាប់ពីឆ្នាំ-- ទសវត្សរ៍ឆ្នាំ៧០ គឺថាចាប់ពីឆ្នាំ១៩៧៣។

**ស៖** តើជនជាប់ចោទអាចពន្យល់ជូនដល់អង្គជំនុំជម្រះ តើមានអ្វីកើតឡើងដោយជាក់ស្ដែងនោះកើតឡើងដែលពាក់ព័ន្ធនឹងលុយ ក្រដាសប្រាក់នៅសម័យនោះ? បើតាមគាត់ដឹងនោះ តើមានការព្រាងទុកដែរឬទេ ថាមានការគ្រោងបោះលុយនៅសម័យ-- គឺថាដើម្បីជំនួសលុយ ប្រាក់កាសរបស់របបសាធារណរដ្ឋ លន់ នល់ នោះ?

[០៩:២០:០២]

**លោក នួន ជា៖**

**ឆ៖** សូមគោរពបងប្អូនរួមជាតិទាំងអស់ក្នុងទីនេះ នៅត្រង់ទីនេះ សូមគោរពលោកប្រធាន។ ខ្ញុំសូម-- វាបញ្ហាហ្នឹងវាយូរហើយដែរ វាមានភ្លេចមានភ្លាំង ការណ៍ដែលមិនបានចាយលុយ មិនទាន់ចាយលុយ ដែលបោះ លុយហ្នឹងបោះហើយ ដើម្បីជំនួសលុយ លន់ នល់ ក៏ប៉ុន្តែមិនទាន់បានចាយ ពីព្រោះអី? ពីព្រោះសភាពការណ៍វានៅស្មុគស្មាញណាស់។ ហើយពេលនោះមានសហករណ៍ បញ្ហាអីៗដោះដូរតាមសហករណ៍សិនទៅ ចាំកាលណាយើងបង្កបង្កើនផលបាន អាចនឹងធានាតម្លៃលុយយើងបាន ចាំយើងចាយលុយ។ ក៏ប៉ុន្តែបញ្ហានេះមិនទាន់បានសម្រេចតាមសំណូមពរទេ វាកើតសង្គ្រាមជាបន្តបន្ទាប់មករវាងសាធារណរដ្ឋសង្គមនិយមវៀតណាម ហើយនិងកម្ពុជាប្រជាធិបតេយ្យ។ តាំងពីដើម-- តាំងពីឆ្នាំ១៩៧៥ មក។ ដូច្នោះ ដូចខ្ញុំសូមជម្រាបជាសង្ខេបខ្លះ ចាប់ផ្ដើម៧៥ ភ្លាម ដើមខែឧសភា កងទ័ពវៀតណាមឈ្លានពានហ្នឹងបានចូលក្នុងបរិវេណតាមឆ្នេរសមុទ្រខាងខេត្តកំពត។ បើលោកប្រធានអនុញ្ញាតខ្ញុំនឹងរៀបរាប់ហួរហែ។ ប៉ុន្តែក៏កុំឲ្យវាវែង មិនវែងពេកទេ។ ខ្ញុំរៀបរាប់ជាឆ្នាំៗតែម្ដង។

[០៩:២៣:១៣]

**ប្រធានអង្គជំនុំ៖**

ព្រឹត្តិការណ៍នេះ លោកបាននិយាយច្រើនលើកច្រើនសាហើយ ដូច្នេះមិនបាច់និយាយទៀតទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោក នួន ជា បាទសំណួរខ្ញុំមានលក្ខណៈច្បាស់លាស់ជាងនេះ គឺថាខ្ញុំចង់ដឹងថា តើដែលជាក់ស្ដែងនោះមានរឿងអ្វីកើតឡើងចំពោះប្រាក់កាស ក្រដាសប្រាក់ដែលឯកជន មនុស្សឯកជនមាននោះ តើមានរូបិយប័ណ្ណបរទេសដែលមនុស្សឯកជននេះកាន់កាប់ដែរឬទេ? ហើយបើសិនជាកម្ពុជា

ប្រជាធិបតេយ្យ ឬក៏បក្សកុម្មុយនីស្តកម្ពុជានោះប្រើប្រាស់តម្លៃរូបិយប័ណ្ណដើម្បីជាប្រយោជន៍របស់ខ្លួន ជាពិសេសគឺថាតើមានការទិញអាវុធ ឬក៏គ្រាប់រំសេវ ដែរឬទេ? ហើយបើមានគឺទទួលការផ្តល់-- មានការទទួលផ្តល់ជំនួយបែបណា? ហើយបើមានការដោះដូរនោះ ដោះដូររបៀបណា?

**លោក នួន ជា៖**

**ឆ៖** គោរពលោកប្រធាន។ តាមខ្ញុំចាំ គ្មានការជំនួយអី ជាលុយជាកាក់អីមកពីណាទេ។ ខំបង្កបង្កើនផលខ្លួនឯង។ ឯអាវុធយុទ្ធភណ្ឌអី អង្កាល់ណោះប្រទេសចិនប្រជាមានិត គេជួយ តាមរយៈវៀតណាម។ វៀតណាម គេដឹកឲ្យ។

[០៩:២៥:២៤]

**ស៖** តើដោយជាក់ស្តែងនោះ តើប្រជាជនមូលដ្ឋានពេញ អាចពេញ អាចឆ្លើយតបនឹងតម្រូវការរបស់ខ្លួនជាចំណីអាហារ សម្លៀកបំពាក់ ឬថ្នាំសង្កូវនោះ តាមរបៀបណា? តើមានការផ្តល់ទៅឲ្យគាត់នូវតម្រូវការទាំងអស់នេះ ឬក៏មានការដោះដូររវាងប្រជាជនមូលដ្ឋានទាំងអស់នេះ?

**ឆ៖** គោរពលោកប្រធាន បញ្ហានេះអនុវត្តទៅតាមសភាពការណ៍កន្លែងនីមួយៗ។ បើកន្លែងណានៅជិតព្រំដែនថៃ កាលនោះប្រើប្រាក់បាតថៃ ដោះដូរទៅ។ យើងមានផលិតផលយកទៅលក់ ហើយក៏គេទិញ។ អានេះទៅតាមកន្លែងនីមួយៗ ឯទូទាំងប្រទេស កាលណោះប្រើសហករណ៍ៗនេះជាអ្នកទិញសម្ភារៈគ្រប់យ៉ាងមកពីប្រទេសថៃ ហើយយកមកដោះដូរជាមួយផលិតផលដែលប្រជាជនកម្ពុជា ដែលសមាជិកសហករណ៍បង្កបង្កើនផលបាន។

[០៩:២៧:០៧]

**ស៖** តើអ្នកណាជាអ្នកកាន់កាប់រូបិយប័ណ្ណបាតរបស់ប្រទេសថៃ ឬក៏ជាការបុគ្គលឯកជន ឬក៏ជាអ្នកទទួលខុសត្រូវមូលដ្ឋាន ឬក៏ជាអ្នកទទួលខុសត្រូវក្នុងបក្សកុម្មុយនីស្តកម្ពុជា? តើបញ្ហានេះមានការរៀបចំឡើងយ៉ាងដូចម្តេចដែរ?

**ឆ៖** បញ្ហា-- គោរពលោកប្រធាន បញ្ហានេះ ខាងផ្នែករដ្ឋបាលទទួលខុសត្រូវ ហើយខាងខ្ញុំទទួលខុសត្រូវខាងបក្ស ឯខាងការអប់រំទេ។ ដូច្នោះការដឹងល្អិត ពីរឿងលុយកាក់អី ខ្ញុំមិនបានដឹងទេ។

**ស៖** តើនៅក្នុងរដ្ឋបាល អ្នកណាជាអ្នកទទួលបន្ទុកក្នុងកិច្ចការទាំងអស់នេះ? តើបញ្ហាទាំងអស់នេះកើតឡើងជាប្រចាំថ្ងៃឬក៏យ៉ាងណា?

**ឆ៖** គោរពលោកប្រធាន សំណួរចុងក្រោយ ខ្ញុំមិនយល់។ កើតឡើងប្រចាំថ្ងៃយ៉ាងម៉េចៗ?

**ស៖** លោក នួន ជា លោកបាននិយាយថា គឺ-- រដ្ឋបាលជាអ្នកទទួលបន្ទុកក្នុងបញ្ហាទាំងអស់នេះ ជាពិសេសគឺថាទាក់ទងទៅនឹងការទិញ ឬក៏ការដោះដូរដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន។ ខ្ញុំសួរលោកថា តើអ្នកណាដោយច្បាស់លាស់តែម្តងនោះ នៅក្នុងរដ្ឋបាលដែលជាអ្នកទទួលខុសត្រូវក្នុងបញ្ហាទាំងអស់នេះ? នេះជាបញ្ហាសំខាន់បំផុត ពីព្រោះវាពាក់ព័ន្ធនឹងជីវិតប្រចាំថ្ងៃរបស់ប្រជាជន។

[០៩:២៩:១៥]

**ឆ៖** គោរពលោកប្រធាន បញ្ហានេះ ដូចខ្ញុំបានជម្រាបហើយ គឺខាងណោះ ខាងផ្នែករដ្ឋាភិបាល ឯខាងខ្ញុំខាងផ្នែកអប់រំ ខាងបក្ស។ ដូច្នោះ ខ្ញុំក្តាប់បញ្ហានេះមិនបានទេ។

**ស៖** លោក នួន ជា លោកខ្លួនផ្ទាល់តែម្តង គឺថាលោកកាលណោះបង្ខំចិត្តធ្វើការដោះដូរដើម្បីបំពេញតម្រូវការផ្ទាល់ខ្លួនរបស់លោក ឬក៏យ៉ាងណា? ហើយកាលនោះ លោកធ្វើយ៉ាងម៉េច ដើម្បីស្លៀកពាក់ ដើម្បីស្រស់ស្រូបអាហារ ដើម្បីទទួលយកថ្នាំសង្កូវនោះ?

**ឆ៖** គោរពលោកប្រធាន បញ្ហានេះ ដូចខ្ញុំបានជម្រាបហើយ អ្នកដែលគេមានថវិកាខ្លះគេដោះដូរខាងថៃ ឯក្រៅពីនេះមានជំនួយបរទេស ដូចជា ខោ អាវ ស្លៀកពាក់ សំពត់ កំណាត់អីៗអាហារបរិភោគអីៗនេះ គឺជំនួយបរទេស គឺជាពិសេសជំនួយខាងចិនប្រជាមានិតគេជួយ។

**ស៖** តើអ្នកណាជាអ្នកសម្រេចក្នុងការចែកចាយ ទៅដល់ប្រជាជននៅក្នុងសហករណ៍? តើការងារនេះត្រូវបានរៀបចំឡើងយ៉ាងដូចម្តេច? តើលោកបានទទួលវត្ថុចាំបាច់ទាំងអស់ សម្រាប់តម្រូវការរបស់លោកផ្ទាល់ខ្លួននោះតាមរបៀបណា?

[០៩:៣១:១៥]

**ឆ៖** សូមគោរពលោកប្រធាន បញ្ហានេះ គឺទុកជាភារកិច្ចរបស់សហករណ៍ គេចែកឲ្យសមាជិកសហករណ៍ បានមកមានត្រូវ-- សហករណ៍ត្រូវការអី សមាជិកសហករណ៍ត្រូវការអី គឺគេខាងសហករណ៍គេប្រជុំគ្នាចែក ឯគ្មានអីចែកផ្ទាល់ខ្លួនឲ្យខ្ញុំទេ។

**ស៖** លោក នួន ជា គឺថាលោកបាននិយាយថា លោកជាអ្នកទទួលបន្ទុកក្នុងការបណ្តុះបណ្តាលអប់រំ នេះជាអ្វីដែលលោកបានលើកឡើងតាំងពីដើមសវនាការ។ តើនៅពេលដែលលោកផ្តល់ការអប់រំនោះតើលោកបានចុះទៅតាមភូមិភាគ ស្រុក ឬក៏សហករណ៍ដែរឬទេ? តើលោកមានដែលចាប់អារម្មណ៍ចង់ដឹងថាតើមានការបំពេញតម្រូវការរបស់ប្រជាជន ឬទេ? តើលោកមានបានចោទសំណួរសួរខ្លួន

ឯងដែរឬទេ ទាក់ទងនឹងបញ្ហានេះ? តើលោកបានមានចុះទៅស៊ើបអង្កេតអីដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន-- គោរពលោកប្រធាន។ ពេលខ្លះខ្ញុំមិនបានចុះញឹកញាប់ទេ ឯការចុះទៅនេះសម្រេចនឹងខាងគណៈភូមិភាគ គេឲ្យចុះទៅកន្លែងណា គេនាំទៅកន្លែងហ្នឹង។ មិនបាន ខ្ញុំក៏មិនបានចុះទៅគ្រប់ភូមិភាគដែរទេ ប៉ុន្តែខ្ញុំទៅក៏ឃើញកន្លែងខ្លះក៏ខ្វះខាត កន្លែងខ្លះក៏មាន ឯកន្លែងខ្វះខាត ក៏គេខំបង្កបង្កើនផលតទៅទៀតទៅ វាមិនមានគ្រប់ស្មើគ្នាទាំងអស់ទេ។

[០៩:៣៣:៤២]

**ស៖** តើកាលនោះមានកង្វះខាតអ្វីនៅសម័យនោះ?

**ឆ៖** សូមគោរពលោកប្រធាន សម័យនោះដូចជាមិនសូវខ្វះខាតអីទេ ខ្វះខាតអីបំពេញខ្លួនឯងទៅបង្កបង្កើនផលទៅ ព្រោះសភាពការណ៍វា ដូចខ្ញុំជម្រាបអ៊ីចឹងវាមិនបរិបូរអីទេ ក៏ប៉ុន្តែថាឲ្យវាគ្រប់គ្រាន់ណាស់ក៏វាមិនគ្រប់គ្រាន់ ពីព្រោះសភាពការណ៍ ខ្ញុំនិយាយឲ្យៗទូលាយបន្តិចចុះ កងទ័ពវៀតណាមក៏ចូលទៅហ្នឹងអីក៏ចូលទៅហ្នឹង។ កាលនោះវៀតណាមហ្នឹងគេធ្វើសង្គ្រាមតាំងពីបំពាក់អាវុធ ធ្វើសង្គ្រាមអាវុធហ្នឹង អាមេរិកទម្លាក់គ្រាប់បែកអីៗច្រើនសន្ធឹកសន្ធាប់ណាស់។ ដូច្នោះប្រជាជនហ្នឹងជម្លៀសឡើង ជម្លៀសចុះ ផ្លាស់ទៅកន្លែងនេះកន្លែងនោះ។ ដូច្នោះហ្នឹងវាពិបាកដោះស្រាយ។ សហករណ៍ហ្នឹងបន្តិចផ្លាស់ទៅនេះបន្តិចផ្លាស់ទៅនោះ។ នេះខ្ញុំសូមជម្រាប សភាពការណ៍ វាមិន-- វាគ្មានសន្តិសុខ ជម្រាបឲ្យត្រង់អ៊ីចេះចុះ។

[០៩:៣៥:០៩]

**ស៖** ខ្ញុំចោទសំណួរម្តងទៀត លោកនិយាយថា មានកង្វះខាត និងខ្វះបុគ្គលិក លោកបានលើកឡើងថា ពុំមានបញ្ហាអ្វីទេ ទាក់ទងទៅនឹងការផ្គត់ផ្គង់ស្បៀងអាហារ។ តើកង្វះខាតនោះ ជាកង្វះខាតអ្វីដែលថាកង្វះខាត ដែលលោកបានសង្កេតឃើញនោះ តើវាពាក់ព័ន្ធនឹងអ្វីខ្លះ?

**ឆ៖** សូមគោរពលោកប្រធាន ការខ្វះខាតហ្នឹង ក៏ខ្វះ ជួនណា ខ្វះអង្ករ ប៉ុន្តែដោះដូរគ្នាបាន បរិវេណខ្លះ គេធ្វើបាន ដីល្អ ធ្វើបានស្រូវអង្ករច្រើន ក៏ដោះដូរជាមួយកន្លែងសហករណ៍ដែលខ្វះខាត។ ដូច្នោះ ជួយគ្នាទៅវិញទៅមក។ ដូច្នោះ ចេះតែដោះស្រាយបាន។ ក៏ប៉ុន្តែដូចខ្ញុំជម្រាបអ៊ីចឹង ឲ្យគ្រប់គ្រាន់នោះ វាមិនគ្រប់គ្រាន់ទេ ប៉ុន្តែមិន-- ល្មមរស់ចែកគ្នារស់ បើនិយាយរួមទៅ ចែកគ្នារស់បាន។

**ស៖** តើពាក់ព័ន្ធកង្វះបុគ្គលិកនោះ តើលោកចង់និយាយថាយ៉ាងម៉េច មានខ្វះបុគ្គលិក?

**ឆ៖** សូមគោរពលោកប្រធាន ដែលខ្ញុំថាខ្វះបុគ្គលិកហ្នឹង គឺខ្វះបុគ្គល ខ្វះមនុស្សជួយចាត់ចែង

ឲ្យច្រើនណ៎ា ពេលនោះ ចូលកងទ័ពទៅភាគច្រើនអស់ហើយ។ ដូច្នោះ នៅសហករណ៍នោះ ច្រើនតែចាស់ៗ ប៉ុន្តែមិនចាស់ប៉ុន្មានទេ ប៉ុន្តែថាកម្លាំងពលកម្មវាមិនគ្រប់គ្រាន់។

**ស៖** អម្បាញ់មិញនេះ គឺលោកបានលើកឡើងផងដែរ ថាលោកមានបានជំនួយពីប្រទេសចិន ឧទាហរណ៍ គឺថាអាវុធដែលផ្ដល់ឲ្យចិននោះ គឺថាផ្ដល់តាមរយៈប្រទេសវៀតណាម។ តើលោកអាចលម្អិតអំពីជំនួយនេះ បានដែរឬទេ? តើជាជំនួយ ដែលថាមិនមានសំណងអីវិញទេ ដូចជាសម្ភារៈយោធាដែលលក់ឲ្យប្រទេសកម្ពុជា ដែលជាកម្មវត្ថុនៃការផ្ដល់កម្ចី ឬក៏ផ្ដល់ជំនួយ តើបរិមាណនៃសម្ភារៈយោធានោះ វាដល់កម្រិតណា តើលោកអាចបញ្ជាក់អំពីតម្លៃ ដែលទិញសម្ភារៈយោធាទាំងអស់នេះ បានដែរឬទេ?

[០៩:៣៨:៣១]

**ឆ៖** សូមគោរពលោកប្រធាន ដូចខ្ញុំបានជម្រាបហើយ ថាខ្ញុំមិនទទួលខាងផ្នែកយោធាទេ ហើយឲ្យខ្ញុំទៅដឹងថាប៉ុន្មាន អីប៉ុន្មាន ក៏ប៉ុន្តែតាមខ្ញុំដឹងណ៎ា មិនមែនទៅចេះតែដាក់ ន៎ែ ជំនួយអាវុធតាមខ្ញុំដឹង ជួនណាវាច្រឡំទៅណោះ ច្រឡំទៅណោះ ខាងវៀតណាម គេដឹកមកឲ្យហ្នឹង ជួនណាគេកាច់យកមួយភាគបីទៅអីទៅ។ ហេតុដូច្នោះហ្នឹង ជួនណា គេច្រឡំ គេថាច្រឡំយកទៅឲ្យរណសិរ្សរំដោះជាតិ ទម្រាំតែសើរើ រើឡើងរើចុះ។ ដូច្នោះហ្នឹង វាច្របូកច្របល់ណាស់ ជម្រាបឲ្យត្រង់ចុះ។ វាមិនមែនបានមកភ្លាមទេ ពីព្រោះយើងក៏ខ្វះបុគ្គល ខ្វះមនុស្ស ដើម្បីនឹងគ្រប់គ្រង ហើយជួនណា កប៉ាល់ហោះវាទម្លាក់ខ្មោចខ្ចីអស់។ ជាក់ស្តែង ដូចជានៅខាងត្បូង ខាងអីអ៊ីចឹង។ កាលណោះ យើងត្រៀមរំដោះភ្នំពេញ សុំឲ្យវៀតណាមហ្នឹង គេប្រគល់អាវុធឲ្យយើងហ្នឹងបីដណ្ដប់ឡាន ដល់គេដឹកយកមកឲ្យកប៉ាល់ហោះទម្លាក់ខ្មោច។ អានោះ ខ្ញុំចូលល្អិតបន្តិចចុះ។

[០៩:៤០:១៦]

**ស៖** បើខ្ញុំយល់ថា លោកមិនដឹងអំពីបញ្ហាលម្អិតទាក់ទងទៅនឹងបញ្ហាផ្គត់ផ្គង់សម្ភារៈទាំងអស់នេះទេ។ ក៏ប៉ុន្តែខ្ញុំគិតថា ប្រហែលជាលោក ប្រហែលជាអាចជម្រាបជូនអង្គជំនុំជម្រះថា តើអាវុធទាំងអស់នេះត្រូវបានផ្ដល់ឲ្យប្រទេសកម្ពុជា ឬក៏លក់ឲ្យប្រទេសកម្ពុជា ឬក៏ជាកម្ចីដោយយកការប្រាក់ ដែលអំពីសំណាក់សាធារណរដ្ឋប្រជាមានិតចិន ឬក៏លោកចង់ជម្រាបជូនយើងថា សំណួរ-- បញ្ហាទាំងអស់នេះពុំដែលត្រូវបានពិភាក្សានៅក្នុងកិច្ចប្រជុំ ដែលលោកបានធ្វើជាមួយអ្នកទទួលខុសត្រូវនៃបក្សកុម្មុយនីស្តកម្ពុជានៅសម័យនោះ?

[០៩:៤១:២១]

**ផ៖** គោរពលោកប្រធាន តាមខ្ញុំដឹង វាជាជំនួយអាវុធៗមួយផ្នែក ជំនួយជាក្រណាត់ វាជាជំនួយឥតលក្ខខណ្ឌ គ្មានសង គ្មានអ្វីវិញទេ ឲ្យទទេ។

**សៈ** ដូច្នេះ បានន័យថាជាអំណោយ គឺថាដោយឥតមានយកថ្លៃអីទេ មែនទេ?

**ផ៖** គោរពលោកប្រធាន ត្រូវហើយ។

**សៈ** ហើយបញ្ហាហ្នឹង គឺថាកើតមានឡើងរហូត គឺធ្វើឡើងតាមរបៀបហ្នឹង ឬក៏យ៉ាងម៉េច?តើសាធារណរដ្ឋប្រជាមានិតចិនតែងតែផ្តល់ជំនួយ ការផ្គត់ផ្គង់សម្ភារៈយោធាដោយឥតគិតថ្លៃដល់ប្រទេសកម្ពុជា ឬក៏នៅពេលណាមួយ ការអនុវត្តបែបនេះត្រូវបានផ្លាស់ប្តូរ ហើយបែរមកលក់ឲ្យប្រទេសកម្ពុជាវិញ?

**ផ៖** គោរពលោកប្រធាន។ ជំនួយខាងអាវុធមួយផ្នែក ខាងប្រទេសចិនប្រជាមានិត គេជួយតាមរយៈវៀតណាម។ ប៉ុន្តែមួយផ្នែកទៀត យើងរឹបកាលណោះ យើងរើយកបានពីសត្រូវ ពីពួកទាហានលន់ នល់ ដែលរត់ចូលសារភាព គឺអីៗអស់នេះ។ ឯជំនួយនេះ ក៏វាជួយរហូតមក។ ជំនួយចំនួនប៉ុន្មានៗខ្ញុំមិនដឹងទេ ពីព្រោះខ្ញុំមិនបានកាន់ខាងជំនួយ។ ដូចខ្ញុំជម្រាបអ៊ីចឹង ជម្រាបហើយ ជម្រាបទៀត គឺខ្ញុំមិនមែនខាងយោធាទេ។

[០៩:៤៣:៤៧]

**សៈ** ប្រហែលជាមានបញ្ហាបកប្រែហើយមើលទៅ។ ពីព្រោះសំណួរខ្ញុំគឺថា តើ នៅពេលណាមួយប្រទេសចិនបានលក់សម្ភារៈយោធាដល់ប្រទេសកម្ពុជា ជាជាងការផ្តល់ជាអំណោយនោះ? តើសំណួរខ្ញុំច្បាស់លាស់ដែរឬទេ?

**ផ៖** គោរពលោកប្រធាន។ គ្មានលក់ទេ ជំនួយខ្ញុំជម្រាបហើយថា ជំនួយឥតលក្ខខណ្ឌ។

**សៈ** តើក្រៅពីការផ្តល់ជំនួយជាសម្ភារៈនេះ តើមានជំនួយជាអ្នកបច្ចេកទេស-- ទីប្រឹក្សាបច្ចេកទេសដែលផ្តល់ជូនដោយសាធារណរដ្ឋប្រជាមានិតចិនដែរឬទេ?

**ផ៖** គោរពលោកប្រធាន មានអ្នកជំនួយខាងបច្ចេកទេស ខាងរទេះភ្លើង មកជួយមើលផ្លូវរទេះភ្លើង ពីព្រោះកាលណោះ យើងរៀបចំផ្លូវរទេះភ្លើងឡើងវិញ។

ប៉ុន្តែគ្មានអ្នកជំនួយខាងនយោបាយ ខាងអីៗគ្មានទេ មានតែអ្នកជំនួយខាងបច្ចេកទេសប៉ុណ្ណឹង។

**សៈ** លោក នួន ជា ក្នុងចំណោមសម្ភារៈយោធា ដែលប្រទេសចិនផ្តល់ឲ្យនោះ តើមានអាវុធ

ប្រភេទណាខ្លះ? តើជាកាំភ្លើងអាកាទេ កាំភ្លើងវែង? ឬក៏មានកាំភ្លើងធំ? ឬក៏រថក្រោះ ឬក៏កាំភ្លើងជាដូចជា បេអឺជាដើម តើមានសម្ភារៈបែបណាខ្លះ?

[០៩:៤៦:១០]

**ឆ៖** គោរពលោកប្រធាន តាមខ្ញុំដឹង ដោយច្រើនកាំភ្លើងដៃ គឺកាំភ្លើងវែង ឯរថក្រោះក៏ខ្ញុំមិនសូវដឹងដែរទេ។ ហើយបេ មានកាំភ្លើង បេ គេហៅ បេ ៧៥០-- កាំភ្លើងបេ។ ពីព្រោះខ្ញុំមិនជំនាញខាងអាវុធទេ។

**ស៖** បាទ សំណួរខ្ញុំដូចតទៅនេះ តើ FALPNK មានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ ឬចំណេះដឹងគ្រប់គ្រាន់ផ្នែកយោធាក្នុងការប្រើប្រាស់សម្ភារៈយោធា ដែលផ្តល់ជូនដោយសាធារណរដ្ឋចិននេះដែរឬទេ? ឬក៏ចំពោះកម្មាភិបាលមួយចំនួននោះត្រូវតែទទួលការបណ្តុះបណ្តាល ហើយតើអ្នកណាជាអ្នកផ្តល់ការបណ្តុះបណ្តាលទាំងអស់នេះ?

**ឆ៖** គោរពលោកប្រធាន កាំភ្លើងអស់នេះមិនបាច់មានអ្នកណាទេ យកមកប្រើបាន ព្រោះសុទ្ធតែកាំភ្លើងធម្មតាភាគច្រើន។ មិនមែនកាំភ្លើងបាញ់កប៉ាល់ហោះ កាំភ្លើងអីឯណាទេ កាំភ្លើងដៃ។ ដូច្នោះវាគ្មានអីលំបាកទេ កងទ័ពយើងឲ្យមកប្រើបានភ្លាម។

[០៩:៤៨:១២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធានខ្ញុំលែងមានសំណួរចោទទៅជនជាប់ចោទហើយ ក៏ប៉ុន្តែខ្ញុំមានឯកសារមួយចំនួនដើម្បីបង្ហាញ។ ខ្ញុំមិនចង់ចោទសំណួរជាក់លាក់ណាទេ ខ្ញុំគ្រាន់តែចង់ឲ្យភាគីក្រុមការពារក្តីរបស់ នួន ជា អាចបញ្ចេញប្រតិកម្ម។ ខ្ញុំនឹងបង្ហាញឯកសារទាំងអស់នេះ ប៉ុន្តែបើសិនជាមានបញ្ហាអីនោះ ខ្ញុំអាចបង្ហាញឯកសារទាំងនេះពេលក្រោយក៏បានដែរ បើសិនជាមានភាគីមួយចំនួនចង់ចោទសំណួរ ឬក៏សហការីរបស់ខ្ញុំចង់ចោទសំណួរទៅជនជាប់ចោទនោះ។

**ប្រធានអង្គជំនុំ៖**

មានទេ តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីផ្សេងទៀត ត្រូវសួរដល់ជនជាប់ចោទ នួន ជា ដែរឬទេ?

បាទ មិនមានទេ ហើយសូមផ្តល់វេទិកាទៅលោក ហ្សង់ម៉ាក ដើម្បីមានឱកាសនៅក្នុងការដាក់ឯកសារភស្តុតាងចំពោះមុខភាគី។

[០៩:៤៩:៣៣]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

ឯកសារទីមួយ ដែលខ្ញុំចង់ដាក់ជូននោះ គឺជាឯកសារដែលមានចំណងថា សុន្ទរកថារបស់សមមិត្ត ប៉ុល ពត លេខាធិការគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងមីទ្ទិងដើម្បីអបអរសាទរខួបលើកទី១៧ នៃការបង្កើតបក្សកុម្មុយនីស្តកម្ពុជា ហើយនិងនៅក្នុងឱកាសនៃការប្រកាសបក្សកុម្មុយនីស្តកម្ពុជាជាផ្លូវការ។ ឯកសារនេះគឺចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ ហើយដែលមានចំណាងជើងថា "ជោគជ័យដ៏មហាធំធេងរបស់បក្សកុម្មុយនីស្តកម្ពុជា ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាដ៏ភ្លឺស្វាង"។ នេះគឺជាឯកសារដ៏វែងមួយដែលមានលេខយោងដូចតទៅនេះ IS4.40 លេខERN ជាភាសាបារាំង S00012471 រហូតទៅដល់ 00012529 ERN ជាភាសាអង់គ្លេស S00012660 រហូតទៅដល់ 00012698 ERN ជាភាសាខ្មែរ 00019250 ទៅដល់ 00019392។ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះគឺទំព័រ ៤៨ រហូតដល់ទំព័រ ៥១ ជាភាសាបារាំង។

ហើយនៅក្នុងសុន្ទរកថានេះ គឺមាននិយាយអំពីបញ្ហាទម្រង់ផ្សេងៗគ្នានៃការតស៊ូបដិវត្តន៍ដែលបានសម្រេចដោយបក្សកុម្មុយនីស្តកម្ពុជានៅក្នុងមហាសមាជ-- មហាសន្និបាតនៅក្នុងទសវត្សរ៍ឆ្នាំ៦០។ ហើយនៅក្នុងឯកសារនោះគឺមាននិយាយដូចតទៅនេះ៖

មហាសន្និបាទលើកទីមួយរបស់បក្ស គឺបានកំណត់អំពីទម្រង់បដិវត្តន៍ដូចតទៅនេះ៖

ទីមួយ) ការប្រើប្រាស់ហិង្សាបដិវត្តន៍ នយោបាយ និងហិង្សាបដិវត្តន៍ប្រដាប់អាវុធ ហើយបន្តទៅទៀត គឺនិយាយថា

ទីពីរ) ទម្រង់នៃការតស៊ូស្របច្បាប់ ពាក់កណ្តាលស្របច្បាប់ និងខុសច្បាប់

ទីបី) ទម្រង់នៃការតស៊ូដោយចំហ ពាក់កណ្តាលចំហ និងលួចលាក់ ឬសម្ងាត់។

ដូច្នេះ ខ្ញុំនឹងអានឃ្លាមួយ គឺមានដូចតទៅនេះ៖

[០៩:៥២:៥០]

ដូច្នេះ បក្សគឺបានយកចិត្តទុកដាក់ក្នុងការបែងចែកការងារក្នុងចំណោមកម្មាភិបាល។ តើសមមិត្តណាខ្លះដែលត្រូវបានផ្តល់ជូននូវការងារដោយចំហ? ហើយអ្នកខ្លះគឺក្នុងមានឋានៈជាតំណាងរាស្ត្រ ហើយអ្នកខ្លះជាសមាជិករដ្ឋាភិបាលនៅក្រោមរបបចាស់ អ្នកខ្លះជាមន្ត្រីរដ្ឋការ ហើយអ្នកខ្លះធ្វើ

ការនៅក្នុងអង្គការមហាជន គឺការងារសារព័ត៌មាន។ ដូច្នេះ ទាំងអស់នេះគឺជាទម្រង់ផ្សេងៗគ្នា ដែលត្រូវបានប្រើប្រាស់ក្នុងការធ្វើឱ្យមានការរំជើបរំជួលដល់មហាជន គឺយើងបែងចែកការងារតាមរបៀបនេះក្នុងចំណោមគ្នាយើងទាំងអស់គ្នា ក៏ប៉ុន្តែគឺយើងមានផ្នែកខាងការងារដោយលួចលាក់ ដើម្បីធ្វើឱ្យមានការរំជើបរំជួលដល់ប្រជាជនដោយលួចលាក់។

[០៩:៥៣:៥៧]

ហើយនៅទីក្រុងភ្នំពេញមានផ្នែកការងារដោយចំហ ហើយនិងមានខាងផ្នែកការងារលួចលាក់។ ហើយនៅជនបទគឺមានផ្នែកការងារបើកចំហ ហើយនិងការងារលួចលាក់ដូចគ្នា។ ការងារលួចលាក់ គឺជាមូលដ្ឋាន គឺអនុញ្ញាតឱ្យយើងការពារកម្លាំងបដិវត្តន៍ ហើយអាចឱ្យធ្វើឱ្យប្រជាជនមានការផុសផុលងើបឡើង ហើយប្រសិនបើយើងទាំងអស់គ្នាធ្វើការងារទាំងអស់នេះបានគឺ-- បើសិនជាយើងធ្វើដោយចំហនោះ គឺខ្មាំងសត្រូវអាចនឹងកម្ទេចយើងបានទាំងអស់។ នេះគឺជាសម្រង់ទីមួយនៃសុន្ទរកថានេះ។

**ស៖** លោក នួន ជា តើលោកមានចងចាំអំពីសុន្ទករថាដែលថ្លែងដោយលោក ប៉ុល ពត នៅថ្ងៃទី ២៧ កញ្ញា ឆ្នាំ១៩៧៧ នេះ តើលោកចងចាំទេនូវអ្វីដែលខ្ញុំបានអានអម្បាញ់មិញនេះ?

[០៩:៥៥:០៩]

**ឆ៖** សូមគោរពលោកប្រធាន ឱ្យខ្ញុំទៅចងចាំយ៉ាងម៉េចបាន បើវាយូរឆ្នាំណាស់ទៅហើយ។ ហើយសុន្ទរកថា-- ប៉ុន្តែបើតាមខ្ញុំស្តាប់ពាក្យដែលលោកមានប្រសាសន៍មកនេះណា ខ្ញុំអាចយល់ខ្លះយ៉ាងនេះ។ បើឱ្យខ្ញុំនិយាយវាវែងបន្តិច ប៉ុន្តែខ្ញុំសរុបឱ្យខ្លីទៅចុះ។ សង្គ្រាមឈ្លប វាមិនមែនសង្គ្រាមសម្បូរបែបទេ។ កាលណោះក្រោយកិច្ចព្រមព្រៀងហ្សឺណែវ វាមានក្រុម គេហៅក្រុមប្រជាជននេះមួយ។ ក្រុមប្រជាជននេះសម្រាប់ធ្វើការងារចំហ ចេញកាសែតអីៗអស់នេះ។ ឯក្រុមមួយទៀតនោះធ្វើការងារសម្ងាត់ ដើម្បីកុំឱ្យ ពីព្រោះការដែលចេញមកពីធ្វើការងារសម្ងាត់នេះ គឺការកសាងបក្សសម្ងាត់។ ឯចំហគេធ្វើតាមចំហទៅ ឯសម្ងាត់ធ្វើតាមសម្ងាត់ទៅ។ អានេះខ្ញុំក្តាប់បានប៉ុណ្ណឹង បើតាមសំណួររបស់លោក។ ឯពាក់កណ្តាលចំហហ្នឹងដូចជាធ្វើបុណ្យ ធ្វើទានអីខ្លះ អ៊ីចឹងព្រោះយើងរូបភាពវាចំហ ប៉ុន្តែជួនណាយើងបញ្ចូលខ្លឹមសារបដិវត្តន៍ខ្លះទៅ អីទៅ។ អាហ្នឹងគេហៅថាពាក់កណ្តាលចំហ ចំហខ្លះ មិនចំហខ្លះ។ អានេះសង្គ្រាមឈ្លបនេះខ្ញុំពិបាកណែំ-- វាធ្វើគ្រប់រូបភាពទាំងអស់ហ្នឹង គឺថារូបភាពអី ឧបមាថា ធ្វើសមាគមក្រុមទាត់បាល់។ រូបភាពដូចជាទាត់បាល់ ក៏ប៉ុន្តែក្នុងការប្រជុំ ក្នុងការនិយាយអី វានិយាយនឹងនយោបាយ។ អាហ្នឹងវាពាក់កណ្តាលសម្ងាត់ ពាក់កណ្តាលចំហ។ បើអធិប្បាយ

ហ្នឹងវាវែង។ ដូច្នោះខ្ញុំសូមមិនអធិប្បាយទេ កុំឲ្យខាតពេល។

[០៩:៥៧:៣២]

**ស៖** លោក នួន ជា តើលោកអាចជម្រាបជូនយើងបានទេថា លោកយល់ស្របជាមួយឃ្លាដែលខ្ញុំអានអម្បាញ់មិញនេះ គឺឃ្លាថា គឺថាមានប្រភេទនៃកម្មាភិបាលខ្លះ គឺថាត្រូវបានប្រគល់ជូនការងារចំហ ហើយកម្មាភិបាលខ្លះទទួលការងារជាសមាជិករដ្ឋសភា ឬក៏ជាសមាជិករដ្ឋាភិបាលនៃរបបចាស់ តើទាំងអស់នេះ គឺជាសេចក្ដីសម្រេច ឬក៏ជាមាគ៌ានយោបាយ ដែលសម្រេចដោយបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** សូមគោរពលោកប្រធាន ដូចខ្ញុំបានជម្រាបហើយ គឺខ្ញុំទទួលតែខាងអប់រំ ឯខាងផ្នែកសម្ងាត់ ផ្នែកចំហ ឬក៏ក្នុងរដ្ឋសភា ក្នុងអីនោះ វាមានផ្នែកដោយឡែករបស់គេសម្រាប់ធ្វើការងារចំហយកមាគ៌ានយោបាយរបស់បក្សទៅច្នៃប្រឌិដ្ឋ ផ្សាយនៅក្នុងកសិករ នៅក្នុងប្រជាជន ឬក៏ក្នុងរដ្ឋសភាពេលនោះហៅថា អ្នកចម្រើន។ អ្នកចម្រើនខ្លះគេទទួលយកមាគ៌ារបស់យើងទៅអនុវត្ត។

[០៩:៥៩:៣០]

**ស៖** តើអ្នកណាដែលស្ថិតនៅក្នុងក្រុមនេះខ្លះ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនស្គាល់ទេ ពីព្រោះអីចេះ ន៎ ដូចខ្ញុំជម្រាបម្ដងហើយ ពីរបីដងហើយណ៎ា ប៉ុល ពត ហៅខ្ញុំទៅប្រាប់ថា មិត្តកុំទៅរវល់ខាងផ្នែកបញ្ញាជន ខាងផ្នែកស្អីៗគេខាងណោះចំហនោះ។ មិត្តគិតតែពីខាងអប់រំទៅ ពីព្រោះមិត្តអនុវត្តនយោបាយជាមួយបញ្ញាជនអីៗហ្នឹង វាមិនផ្លូវផង់ ហើយខ្ញុំក៏មិនរវល់អី ខ្ញុំគិតតែពីខាងអប់រំបក្ស។ ខ្ញុំជម្រាបច្រើនដងហើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណ។ ខ្ញុំមិនដឹងថា តើជនជាប់ចោទ ខៀវ សំផន គាត់ចង់មានបន្ទាប់ប្រតិកម្មអ្វីទេ? គឺថាលោក ខៀវ សំផន អាចមានលទ្ធភាពក្នុងការធ្វើប្រតិកម្មតបបាន ប្រសិនបើលោកចង់។

**លោក ខៀវ សំផន៖**

សូមជម្រាបលោកប្រធាន សូមជម្រាបអង្គប្រជុំ។ ខ្ញុំអត់មានអត្ថាធិប្បាយអីទាំងអស់។ ព្រោះការងារទាំងអស់ហ្នឹង វាតាំងពីឆ្នាំ៦០ តាំងពីស្អីណាមក ខ្ញុំអត់ដឹងសោះ។ ខ្ញុំអត់ដឹងទេ ខ្ញុំអត់យល់ទេ។ ខ្ញុំបានជម្រាបលោកប្រធានកាលពីក្នុងអន្តរាគមន៍របស់ខ្ញុំកាលខែមុនៗហ្នឹង ហើយខ្ញុំចូលបក្សនៅពេលណា? ខ្ញុំចូលបក្សនៅភ្នំឱរ៉ាល់ គឺឆ្នាំ៦៩ ជិតរដ្ឋប្រហារហើយ។ ដូច្នេះ មុនៗហ្នឹង ខ្ញុំអត់ដឹងអីទាំងអស់។

សូមអរគុណ បាទ។

[១០:០១:៥៣]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ដូច្នេះ ខ្ញុំសូមចូលទៅឯកសារផ្សេងទៀត គឺឯកសារពាក់ព័ន្ធទៅនឹងចលនាប្រជាជននៅទីក្រុង ហើយដែលត្រូវបានជម្លៀសចេញពីតំបន់ប្រយុទ្ធគ្នា ហើយទៅកាន់តំបន់នៅក្រោមការគ្រប់គ្រងរបស់កងទ័ពប្រជាជនរំដោះជាតិកម្ពុជា។ គឺជាពិសេសនៅស្ថានភាពនៅឧដុង្គ នៅពេលដែលការវ៉ៃយកឧដុង្គនៅឆ្នាំ១៩៧៤នោះ។

ខាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារនេះរួចមកហើយ ប៉ុន្តែជនជាប់ចោទ ខៀវ សំផន គឺគាត់អាចមានការអត្ថាធិប្បាយនៅល្ងាចនេះបាន។ ដូច្នេះ ខ្ញុំសូមបង្ហាញនូវឯកសារ E3/25 គឺជាឯកសារទស្សនាវដ្ដីទង់បដិវត្ត លេខពិសេស ខែ-- លេខD176 ហើយនៅខែមករា ឆ្នាំ៧៧ គឺថាសម្រង់សុន្ទរកថារបស់តំណាងបក្សនៅក្នុងខួបលើកទីប្រាំបួន នៃការបង្កើតបក្សបដិវត្តន៍-- កងទ័ពបដិវត្តន៍កម្ពុជា ហើយនិងជាកងទ័ពដ៏ខ្លាំងក្លាមហាអស្ចារ្យ។ លេខERN ជាភាសាបារាំង S00504049-00504050 គឺទំព័រ៣៦ និង ៣៧ ជាភាសាបារាំង។ យើងទទួលបានជោគជ័យ ពីព្រោះយើងអាចសម្រេចបាននៅក្នុងការអនុវត្តមាគ៌ាប្រយុទ្ធ តាមរបៀបល្អឥតខ្ចោះបំផុត ដើម្បីនៅពេលដែលដើម្បីកម្ទេចខ្មាំងនៅលើផ្នែកនយោបាយ គឺយើងៗលើកយកឧទាហរណ៍តែមួយគត់នៅក្នុងការទទួលបានការចូលរួមពីប្រជាជនដើម្បីកៀងប្រមូលប្រជាជន ហើយនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោករបស់យើងនេះគ្មាននរណាម្នាក់អាចប្រមូល ឬក៏កៀរប្រជាជនបានបែបនេះទេ។ ក៏ប៉ុន្តែមាគ៌ានយោបាយរបស់យើងគឺធ្វើយ៉ាងណាដើម្បីប្រមូលប្រជាជនឲ្យបានច្រើន ដោយមិនគិតពីចំនួនមនុស្សទេ ទោះបីជាមនុស្សមួយក៏យើងអាចយកដែរ ពីរក៏យើងយក មួយក៏យើងយក។

[១០:០៤:៣៨]

ដូច្នេះយើងត្រូវតែប្រមូលយកប្រជាជនបានទាំងអស់រហូតទាល់ធ្វើយ៉ាងណាឲ្យយើងទទួលបានប្រជាជនពីទីក្រុងភ្នំពេញមកបានទាំងអស់។

មាគ៌ារបស់បក្សដែលប្រមូលប្រជាជនពីខាង-- យកមកពីខាងខ្មាំងនេះ គឺថាវាមានសារៈសំខាន់មានតម្លៃខ្លាំងណាស់នៅក្នុងពិភពលោកយើងទាំងអស់នេះ។ ការធ្វើបែបនេះ គឺមិនដែលធ្លាប់មានតែសោះ។ ប្រសិនបើខ្មាំងកាន់កាប់ប្រជាជននៅក្នុងដៃ។ ដូច្នេះពួកគេមានយោធា ហើយពួកគេក៏មាន

សេដ្ឋកិច្ច ផ្ទុយទៅវិញ ប្រសិនបើពួកគេមិនមានប្រជាជននៅក្នុងដៃនោះទេ ពួកគេគ្មានកម្លាំងយោធា ហើយក៏មិនមានកម្លាំងសេដ្ឋកិច្ចដែរ។ ទទ្ធីករណ៍របស់យើងនេះ គឺមានលក្ខណៈត្រឹមត្រូវល្អណាស់។ ហើយមាគ៌ានយោបាយរបស់យើង គឺមានភាពត្រឹមត្រូវនៅគ្រប់ទីកន្លែងទាំងអស់ដោយគ្មានការលើកលែង។ យើងត្រូវតែកៀងប្រមូលប្រជាជនទាំងអស់ យ៉ាងជាដាច់ខាត។ ហើយក្រោយមកខាងក្រោមទៀត មានការលើកឡើងទៀតថា ឧទាហរណ៍ យើងបានរំដោះឧដុង្គនៅឆ្នាំ៧៤ ហើយបន្ទាប់មកទៀត យើងបានជម្លៀសយកប្រជាជនចេញមកទាំងអស់ពីឧដុង្គ។ ហើយនៅពេលដែលយើងវៃយកកន្លែងនោះ គឺពួកគេខ្មាំងគឺមិនមានកម្លាំងប្រជាជនទៀតទេ ហើយខ្មាំងក៏មិនមានកម្លាំងសេដ្ឋកិច្ច គ្មានកម្លាំងយោធា។ អាស្រ័យហេតុនេះ យើងអាចកម្ទេចពួកគេបាន គឺតាមពិតទៅយើងមិនចាំបាច់វៃពួកគេផង ហើយនៅពេលដែលយើងបានទៅដល់ភ្នំពេញ យើងក៏បានទុកឧដុង្គចោល ហើយបន្ទាប់មកទៀត គឺយើងបានទៅវៃចូលទៅសមរភូមិមុខ។

[១០:០៦:៣១]

នេះគឺជាមាគ៌ាយុទ្ធសាស្ត្រដែលមានសារៈសំខាន់បំផុត។ ដូច្នេះដាច់ខាត យើងត្រូវតែកាន់កាប់ប្រជាជនដើម្បីប្រមូលប្រជាជនយកមកបានទាំងអស់។ អាស្រ័យហេតុនេះហើយបានជា សមាជិកបក្ស ហើយយុទ្ធជន យុទ្ធនារីរបស់យើង និងអំណាចមូលដ្ឋានត្រូវតែយល់ជាដាច់ខាតថា អ្វីដែលប៉ះពាល់ទៅដល់ប្រជាជន គឺជាយុទ្ធសាស្ត្ររបស់យើង។ ហើយនៅក្នុងន័យនេះ ជំរំដែលមានប្រជាជននោះ គឺជាជំរំនោះហើយដែលទទួលបានជោគជ័យ គឺខាងណាមានប្រជាជន ខាងនោះទទួលបានជោគជ័យប្រជាជនមានតម្លៃជាយុទ្ធសាស្ត្រ។ ហើយប្រជាជនក៏មានតម្លៃជាយុទ្ធវិធីដែរ ប្រសិនបើប្រជាជនមានតម្លៃជាយុទ្ធវិធីនៅកន្លែងនៅទីតាំងរបស់យើងនោះ គឺយើងនឹងប្រើប្រាស់ពួកគាត់ ហើយប្រសិនបើពួកគេនៅក្នុងផ្នែករបស់ខ្មាំងនោះ គឺពួកគេនឹងបម្រើខ្មាំងហើយ។ នៅក្នុងភារកិច្ចការពារប្រទេសជាតិ នាពេលបច្ចុប្បន្នក៏ដូចជាពេលអនាគតនោះ ជាចាំបាច់យើងត្រូវតែធ្វើយ៉ាងណាឲ្យកាន់កាប់ក្តោបក្តាប់ប្រជាជនបានទាំងស្រុង។

[១០:០៨:០០]

**លោក នួន ជា៖**

**ជ៖** សួរយ៉ាងម៉េចអានហ្នឹង? ឲ្យខ្ញុំស្តាប់ហើយ? ពីព្រោះអាហ្នឹងវាគោលការណ៍សង្គ្រាមឈ្លបវាអ៊ីចឹងហើយ គោលការណ៍សង្គ្រាម ប្រជាជននៅខាងណា ខាងហ្នឹងឈ្នះ ខាងណា-- យើងពង្រីង

ប្រជាជនពីខ្មាំង។ ដូច្នោះប្រជាជននៅខាងយើងឧបត្ថម្ភយើង ប្រជាជននៅខាងខ្មាំងឧបត្ថម្ភខ្មាំង ហើយ ប៉ុន្តែលោកចង់សួរចំណុចអី? ពីព្រោះគោលការណ៍រួមវាអ៊ីចឹងហើយ ហើយជាពិសេសសង្គ្រាមឈ្លបនេះ វាត្រូវអនុវត្តអ៊ីចឹង។ ប៉ុន្តែយកប្រជាជន ខាងណាមានប្រជាជនច្រើនប្រមូលឲ្យ គឺថាប្រមូលប្រជាជនឲ្យច្រើនជាអតិបរិមា ពង្រឹងប្រជាជនពីខ្មាំង អាហ្នឹងវាត្រូវហើយគោលការណ៍នេះមានអីខុស។

[១០:០៩:៣៩]

**សៈ** អ្វីដែលលោកនិយាយនេះគឺខ្ញុំយល់ថា នៅក្នុងទស្សនវិស័យ នៃសង្គ្រាមឈ្លប នៃការតស៊ូបដិវត្តន៍នោះ គឺថាប្រជាជន គឺត្រូវបានចាត់ទុកថាជាបញ្ហាយុទ្ធសាស្ត្រដ៏សំខាន់ ជាធាតុយុទ្ធសាស្ត្រដ៏សំខាន់។ ខាងណាដែលកាន់កាប់ប្រជាជនបាន គឺនៅខាងនុ៎ងហើយ ជាអ្នកមានប្រៀបនៅក្នុងការតស៊ូនោះ តើអ្វីដែលខ្ញុំយល់នោះ គឺអ៊ីចឹងមែនទេ លោក នួន ជា?

**នៈ** ប៉ុន្តែ-- គោរពលោកប្រធាន ជួនណាទ្រឹស្តីតែមួយ ប៉ុន្តែការយល់វាខុសគ្នា។ បើនិយាយដូចលោកនិយាយអ៊ីចឹងមែន វាត្រូវហើយ។ គឺប្រជាជននៅខាងណា ខាងហ្នឹងវាឈ្នះ ពីព្រោះការអធិប្បាយលទ្ធិ លទ្ធិតែមួយ ដូចៗតែគ្នា ប៉ុន្តែការអធិប្បាយជួនកាលវាខុសៗគ្នា។ ដូច្នោះ ខ្ញុំពិបាកឆ្លើយថាលោកមានប្រសាសន៍ហ្នឹង ត្រូវ ឬខុស យ៉ាងម៉េចនោះ ខ្ញុំពិបាកថាណាស់។ ប៉ុន្តែបើនិយាយត្រង់ៗទៅ ណាខាងណាមានប្រជាជនច្រើន ខាងហ្នឹងឈ្នះ។ ខាងណាគ្មានប្រជាជន ខាងហ្នឹងចាញ់ ក៏ប៉ុន្តែអានេះ វាជាគោលការណ៍រួមៗ។

**សៈ** លោក នួន ជា ចំពោះបញ្ហាដណ្តើមយកប្រជាជន។ បើតាមទស្សនៈរបស់លោក តើជម្រើសនៃសេរីភាពដែលផ្តល់ជូនទៅដល់ប្រជាជននោះ វាមានចំណែកប៉ុនណា? ហើយនិងចំណែកនៃកម្លាំងដែលត្រូវប្រើដើម្បីដណ្តើម កៀរយកប្រជាជននោះ?

[១០:១២:១២]

**នៈ** គោរពលោកប្រធាន ខ្ញុំមិនយល់សំណួរលោកព្រះរាជអាជ្ញា។ លោកសួរឲ្យច្បាស់មក។

**សៈ** លោក នួន ជា សំណួរដែលខ្ញុំសួរនោះ គឺដូចតទៅនេះ នៅពេលដែលត្រូវកៀរប្រមូលប្រជាជន ដណ្តើមយកប្រជាជននោះ តើភាគ ឬក៏ចំណែក នៃសេរីភាពដែលផ្តល់ជូនទៅដោយប្រជាជននោះ វាចំណែកប៉ុនណា? ហើយនិងចំណែកនៃការប្រើប្រាស់កម្លាំងដើម្បីដណ្តើមប្រជាជននោះ?

**នៈ** សូមគោរពលោកប្រធាន។ អាបញ្ហានេះ វាជាក់ស្តែង បើប្រជាជនជួនណា មិនបាច់កៀរទេ ពីព្រោះកប៉ាល់ហោះ វាទម្លាក់មក ប្រជាជនរត់មកចូលតំបន់រំដោះហើយ រត់មកចូលព្រៃអស់ហើយ

មិនបាច់ទៅកៀរ ទៅអីទេ។ មិនបាច់ទៅប្រមូល មិនបាច់ទៅកៀរទេ មកខ្លួនឯងតែម្តង។ ពីព្រោះគាត់រត់-- ជម្រាបពីព្រោះ កាលណោះ បេ៥២ វាទម្លាក់មិនតិចទេ។ រណ្តៅមួយៗ ប៉ុនស្រះ ផ្ទះសម្បែងខ្ទេចខ្ទីអស់ ដូចនៅតាប្រុកអ៊ីចឹង។ តាប្រុក នៅកំពង់នេះ-- ខាងកំពង់ចាម។ ស្លាប់ប្រជាជនអស់មួយចំហៀងភូមិ។ ប៉ុន្តែប្រជាជនដែលគេជម្លៀសមក គេរួចខ្លួនទៅ។

ដូច្នោះ មិនបាច់ទៅប្រើកម្លាំងអីទៅកៀរទៅអីទេ មកខ្លួនឯង រត់មកខ្លួនឯងតែម្តង ជម្លៀសមកខ្លួនតែម្តង។ នេះ ខ្ញុំសូមជម្រាប គោរពលោកប្រធាន។

[១០:១៤:៥៦]

**ស៖** លោក នួន ជា ច្បាស់ណាស់ថា កម្ពុជាទទួលរងនូវការទម្លាក់គ្រាប់បែកជាច្រើន ហើយប្រជាជនត្រូវរត់ភៀសខ្លួន។ ក៏ប៉ុន្តែនៅក្នុងអត្ថបទដែលខ្ញុំដកស្រង់ ដែលខ្ញុំអាននេះ គឺសំដៅទៅដល់ប្រជាជនដែលស្ថិតនៅក្នុងតំបន់វាយប្រហារ តំបន់ប្រយុទ្ធគ្នា គឺតំបន់ដែលមានការប្រយុទ្ធគ្នារវាងកម្លាំងខ្មែរក្រហម គឺកងទ័ពប្រជាជនរំដោះជាតិកម្ពុជា ហើយនិងកម្លាំងសាធារណរដ្ឋ ហើយនិងសម្ព័ន្ធមិត្តរបស់សាធារណរដ្ឋ ហើយនៅក្នុងតំបន់ប្រយុទ្ធនោះ គឺមានប្រជាជន។ ហើយប្រជាជននេះ បើតាមខ្ញុំយល់នោះ គឺថាយើងត្រូវធ្វើម៉េចដណ្តើមយកមកពីខាងខ្មាំង។ ខ្ញុំមិននិយាយអំពីប្រជាជនដែលគេចពីការទម្លាក់គ្រាប់បែក បេ-៥២ នោះទេ។ គឺយើងខ្ញុំសំដៅទៅដល់ប្រជាជនដែលស្ថិតនៅក្នុងតំបន់ប្រយុទ្ធគ្នា។ តើពួកគេមានជម្រើសយ៉ាងណាខ្លះ? ដើម្បី គឺថាពួកគេត្រូវតែទៅតាមកម្លាំងខ្មែរក្រហម ឬក៏នៅកន្លែងហ្នឹងតែម្តង តើយើងត្រូវធ្វើយ៉ាងម៉េចចំពោះប្រជាជនទាំងអស់នោះ? តើខ្ញុំសួរនេះច្បាស់ដែរឬទេ លោក នួន ជា?

**ឆ៖** គោរពលោកប្រធាន អាសង្គ្រាម វាពិបាកនិយាយណាស់។ ជួនណាគេនៅទៅ គេនៅបាន គេនៅទៅ នៅមិនបានទេ ក៏គេគេចមក ប៉ុន្តែភាគច្រើនគេចហើយ ព្រោះគ្រាប់កាំភ្លើង។ ហើយមានអ្នកណាទៅឃាត់ហាមមកបាន។ បាញ់ទៅ បាញ់មក។ អាហ្នឹងទាល់តែ សូមអត់ទោសចុះ ទាល់តែទៅប្រយុទ្ធជាក់ស្តែងបានដឹង បានឃើញសភាពការណ៍ជាក់ស្តែង ប៉ុន្តែបើយើងមកនិយាយគ្នានៅនេះ វាមិនឃើញការជាក់ស្តែងពិបាក។ ពិបាកយល់ដែរ។

**ស៖** តើលោកស្ថិតនៅសមរភូមិប្រយុទ្ធដែរឬទេ លោក នួន ជា?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនដែលស្ថិតនៅក្នុងសមរភូមិប្រយុទ្ធទេ។ ខ្ញុំនៅសមរភូមិក្រោយ ខាងអប់រំ។ ដូចខ្ញុំជម្រាបអ៊ីចឹងខាងអប់រំ នៅសមរភូមិក្រោយ។

**ស៖** ដូច្នេះចំពោះលោក គឺថាការយុទ្ធគ្នានោះ គឺថាមានលក្ខណៈអរូបី គឺថាលោកមិនដែលឃើញមនុស្សដែលត្រូវបានគេជម្លៀសចេញទេ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនសូវបានចេញទៅសមរភូមិ សូមគោរពលោកប្រធាន។ ខ្ញុំមិនដែលបានចេញទៅសមរភូមិផង។ ខ្ញុំនៅខាងក្រោយ ដូចខ្ញុំជម្រាបហើយ។ ឯកងទ័ព គេទៅខាងមុខ នៅប្រជាជននៅមិនបាន គេ-- ជួនណាប្រជាជនរត់ខ្លួនឯងផង មិនបាច់ជម្លៀសទេ ពីព្រោះទៅទ្រាំស៊ូនឹងគ្រាប់កាំភ្លើងម៉េច។ ហើយប្រជាជនដែរទេ។ ហើយខ្លាំង ដូចជម្រាបស្រាប់ហើយ ប្រជាជនល្អក៏វាសម្លាប់ បើចូលកន្លែងប្រយុទ្ធហើយប្រជាជនមិនល្អ ក៏វាសម្លាប់ វាមិនដឹងអីវាទេ។

[១០:១៩:៣៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើជនជាប់ចោទ ខៀវ សំផន ចង់ឆ្លើយតបទៅនឹងឯកសារដែលបានដាក់ជូននេះដែរឬទេលោក ខៀវ សំផន?

**លោក ខៀវ សំផន**

ខ្ញុំបានជម្រាបលោកតុលាការហើយថា ខ្ញុំសូមរក្សាសិទ្ធិមិនឆ្លើយនឹងសំណួរអ្វីទាំងអស់ តាមការអនុញ្ញាតរបស់តុលាការរួចហើយបាទ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** យើងសូមចូលទៅឯកសារផ្សេងទៀត គឺជាអត្ថបទ ហើយនិងសុន្ទរកថាដែលបោះផ្សាយដោយទីភ្នាក់ងារព័ត៌មានកម្ពុជា គឺថាអង្គការនេះ គឺជាអង្គការផ្លូវការនៃព័ត៌មានខាងរណសិរ្ស ហើយនិងរដ្ឋាភិបាលរួបរួមជាតិ។ ឯកសារទីមួយ គឺលេខ IS12.5 នេះគឺជាទស្សនាវដ្ដីដំណឹងពីកម្ពុជា ដែលបោះផ្សាយដោយទីភ្នាក់ព័ត៌មានកម្ពុជា ហើយគឺលេខ៦៩៦ ចុះថ្ងៃទី-- គឺលេខ៤៤.៧០ គឺថាមានថា ប្រជាជនកំពុងតែភ័យខ្លាច ហើយរុញច្រានទៅក្នុងសមរភូមិ ហើយចំណែកឯកងទ័ពប្រជាជនរំដោះជាតិកម្ពុជា គឺថានៅតែមានការផ្ដួចផ្ដើម ហើយនិងវាយប្រហារខ្លាំងដោយឥតឈប់ឈរ។ គឺទំព័រ៥ នៃភាសាបារាំង (សូមទោស) ទំព័រ៧ ហើយលេខERN ជាភាសាបារាំង S00093 ទៅដល់ 0000094 ERNជាភាសាអង់គ្លេស 00280556 ទៅដល់ 00280557 ERN ជាភាសាខ្មែរ S00662247 ទៅដល់ 00662259។

[១០:២២:១៤]

នៅថ្ងៃទី១៥ មីនា ឆ្នាំ៧៤ កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានវាយប្រហារជាថ្មីទៅលើទីក្រុង

ឧដុង្គ ហើយនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ៧៤ គឺបានរំដោះយកទីក្រុងឧដុង្គទាំងស្រុង ហើយកងពលធំខ្មាំងមួយកងពលត្រូវបានកម្ទេច។ ហើយប្រជាជន៣សែននាក់ គឺបានគេចចេញពីតំបន់នេះ ហើយចូលទៅតំបន់រំដោះ។ ហើយបន្ទាប់ពីមានការកម្ទេចពីកងទ័ពពីកងទ័ពខ្មែរក្រហមនេះ គឺប្រព័ន្ធឃោឃានៃអំណាចរបស់សាធារណរដ្ឋ ហើយនិងបន្ទាយនៅឧដុង្គនោះ គឺត្រូវបានធ្វើម៉េចទាមទារឲ្យមានការទាមទារនូវកងជំនួយទៅកាន់តំបន់ឧដុង្គនោះ។ នេះគឺជាអត្ថបទមួយទៀតរបស់ទស្សនាវដ្ដីដដែលនេះ គឺឯកសារ IS12.7 ហើយដកចេញពីលេខ៦៩៨ គឺជាសុន្ទរកថារបស់ឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ដែលបានថ្លែងនៅថ្ងៃទី០៥ ខែ០៤ ៧៤ នៅពេលទស្សនកិច្ចរបស់រណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិនៅកូរ៉េខាងជើង។ ហើយលេខ ERN ជាភាសាបារាំង S000120 ទៅដល់ 122 ERN ជាភាសាអង់គ្លេស 00280584 ទៅដល់ 00280586 ERN ជាភាសាខ្មែរ 00596138 ទៅដល់ 00596141។ នៅក្នុងសុន្ទរកថានេះ គឺមានការ លោក ខៀវ សំផន បានថ្លែងថា នៅថ្ងៃទី១៨ មីនា គឺកម្លាំងរបស់យើងបានរំដោះទីក្រុងមួយទៀត គឺទីក្រុងឧដុង្គ ដោយកម្ទេចទាហានអាយ៉ងទាំងអស់ដែលមាននៅទីនោះ ហើយនិងកងកម្លាំងជំនួយរបស់ពួក គឺប្រហែលជា ៥.០០០នាក់ នៃកងទ័ពខ្មាំងដែលត្រូវបានកម្ទេច ហើយនិងមានចាប់ខ្លួនបានមួយចំនួនទៀត។ លោក នួន ជា តើលោកធ្លាប់និយាយអំពីការវាយយកទីក្រុងឧដុង្គដែរឬទេ? ហើយតើមានអីកើតឡើងចំពោះប្រជាជននៅទីក្រុងឧដុង្គនោះ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំធ្លាប់ឮ ប៉ុន្តែខ្ញុំមិនចាំទេ។ មិនដឹងជាកម្ទេចអស់ប៉ុន្មានអីប៉ុន្មាន។ អ្នកណាទៅចាំ បើមិនដឹងជាប៉ុន្មានឆ្នាំទៅហើយ។

**ស៖** តើលោកដឹងទេថា មានអ្វីកើតឡើងចំពោះប្រជាជនដែលកើតឡើងនៅឧដុង្គ ហើយនិងនៅតំបន់ជុំវិញនោះ ក្រោយពីមានការប្រយុទ្ធគ្នានោះ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនដឹងទេ ព្រោះខ្ញុំមិនបានចុះទៅសមរភូមិ។

[១០:២៥:៥៧]

**ស៖** នៅខែមីនា ឆ្នាំ១៩៧៤ តើលោកអាចជម្រាបបានទេថា លោកនៅទីណាឲ្យបានច្បាស់នោះ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនចាំទេ ព្រោះនៅច្រើនកន្លែង។

**ស៖** ដូច្នេះ តើខ្ញុំចង់ដឹងថាលោក ខៀវ សំផន លោកចង់ឆ្លើយតបអ្វីទេ ឬក៏លោកចង់ជម្រាបជូនអង្គជំនុំជម្រះអ្វីទេចំពោះឯកសារមួយនេះ?

**ផ៖** សូមគោរពអង្គតុលាការ ដូចខ្ញុំបានជម្រាបហើយ ខ្ញុំសូមរក្សាសិទ្ធិនៅស្ងៀមស្ងាត់នៅពេលនេះ ហើយខ្ញុំនឹងមានមតិនៅពេលណាដែលមានភស្តុតាងគ្រប់គ្រាន់លើការចោទប្រកាន់របស់ខ្ញុំដូចខ្ញុំបានជម្រាបជាហូរហែមកហើយៗ តុលាការក៏បានអនុញ្ញាតហើយ។ បាទ សូមអរគុណ។

**ស៖** ដូច្នេះខ្ញុំសូមចូលទៅឯកសារមួយទៀត គឺខ្ញុំចង់ត្រលប់មកឯកសារទីមួយដែលខ្ញុំបានបង្ហាញកាលពីព្រឹកមិញនេះ។ គឺសុន្ទរកថារបស់-- សុន្ទរកថាដែលប្រកាសដើម្បីរំឭកខួបទី១៧ នៃការបង្កើតបក្សកុម្មុយនីស្តកម្ពុជា។ នេះគឺជាសុន្ទរកថារបស់សមមិត្ត ប៉ុល ពត។ ខ្ញុំ ពេលនេះខ្ញុំសូមយោងទៅលើទំព័រ៧១ ជាភាសាបារាំង ហើយឯកសារនេះ គឺឯកសារ IS44.40។ នេះគឺជាសម្រង់នៃសុន្ទរកថាដែលមានចំណងជើងថា “ចលនាបដិវត្តន៍ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា”។ ខ្ញុំសូមដកស្រង់ដូចតទៅនេះ៖

[១០:២៨:៣៥]

បក្សរបស់យើងបានកំណត់មាគ៌ាប្រយុទ្ធ គឺយើងប្រយុទ្ធខាងផ្នែកយោធាផង ខាងផ្នែកនយោបាយ ដោយដកយកប្រជាជន ឬក៏ពង្រឹងប្រជាជនពីខ្មាំង។ ហើយខាងផ្នែកសេដ្ឋកិច្ចៗគឺយើងកាត់ផ្ដាច់ការផ្គត់ផ្គង់ ហើយនៅខាងផ្នែកផ្សេងៗទៀតគឺថា យើងកម្ទេចនូវបណ្ដាញចារកម្មរបស់ខ្មាំង ហើយនិងការតប្រឆាំង-- ហើយយើងធ្វើយ៉ាងម៉េចឱ្យមានចលនាប្រឆាំងទៅនឹងកងទ័ពរបស់ខ្មាំង។

នៅពេលដែលខ្ញុំអានថា បក្សបានកំណត់នូវមាគ៌ាប្រយុទ្ធដែលមានទាំងផ្នែកនយោបាយ ផ្នែកយោធា ហើយដោយដកយកពង្រឹងប្រជាជនពីខ្មាំង តើវាដូចទៅនឹងអ្វីដែលខ្ញុំបានអានបាន ដែលខ្ញុំអានពីមុន ហើយនិងមានសរសេរនៅក្នុងទស្សនាវដ្ដីទង់បដិវត្តដែរឬទេ? ឬមួយក៏ថា វា-- អត្ថបទទាំងពីរនេះមានចំណុចផ្សេងគ្នា?

[១០:៣០:០២]

**ផ៖** គោរពលោកប្រធាន ខ្ញុំមិនចាំទេ អត្ថបទវាច្រើនណាស់។ ហើយ-- ជម្រាបលោកប្រធាន ហើយខ្ញុំមិនបាន-- ដូចខ្ញុំជម្រាបហើយជម្រាបទៀត បើលោកព្រះរាជអាជ្ញាសួរពីខាងអប់រំ រៀនសូត្រអីទៅ ខាងនយោបាយ ខាងសតិអារម្មណ៍ ខាងចាត់តាំងអី ខាងសតិអារម្មណ៍ខាងអីទៅ អាហ្នឹងខ្ញុំឆ្លើយបាន ប៉ុន្តែបើសួរខាងយោធា យោអី ខ្ញុំមិនមែនអ្នកយោធា មិនដែលចុះសមរភូមិផង ឱ្យខ្ញុំទៅឆ្លើយយ៉ាងម៉េច។ គ្រាន់តែឮដំណឹងឮ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយ ខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំគាត់ទៅកាន់កន្លែងកៅអីរបស់គាត់ដែលនៅក្រោយមេធាវីរបស់គាត់ ហើយនិងឲ្យនាំគាត់មកវិញឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

អញ្ជើញក្រោយកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់លោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា ដែលបានស្នើសុំកាលពីព្រឹកមិញ ពាក់ព័ន្ធនឹងបញ្ហាសាក្សី។

លោកមេធាវីអន្តរជាតិការពារក្ដី នួន ជា សូមអញ្ជើញឡើងក្រោកឈរ ដើម្បីស្ដាប់ការបញ្ជាក់របស់អង្គជំនុំជម្រះ។

លោកផេសមិន!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ជាបឋម លោក ផេសមិន ថាតើលោកបញ្ជាក់ថា នៅពេលដែលចៅក្រមសម្រេចដូច្នេះហើយគឺសូមឲ្យលោកត្រឡប់មកតុលាការទាន់ពេល ដូចជាសហសេវិករបស់លោកដែរ។ ទីពីរលោកប្រធានបានសូមឲ្យខ្ញុំចង្អុលបង្ហាញជាការឆ្លើយតបទៅសំណើពីមុនរបស់លោក អំពីឱកាសក្នុងការពិនិត្យអ្នកជំនាញហើយនិងសាក្សីផ្សេងទៀត ទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រនៅក្នុងផ្នែកសវនាការនេះ។ ហើយយើងពិនិត្យឃើញថា ព័ត៌មានទាក់ទងទៅនឹងផ្នែកនេះគឺថា អាចនឹងតាំងសំណួរដោយលោក និងភាគីផ្សេង

ទៀតនៅក្នុងដំណាក់កាលផ្សេងនៃសវនាការ។

[១០:៥៥:៣២]

អង្គជំនុំជម្រះមិនទាន់ប្រាកដថាតើសាក្សីណាទេដែលលោកយោងទៅរកនោះ តើលោកអាចដាក់សំណើជាលាយលក្ខណ៍អក្សរបានទេ? ដើម្បីឱ្យអង្គជំនុំជម្រះ ហើយសូមឱ្យលោកយុត្តកម្មផង ឱ្យសំអាងហេតុផង ថាតើគោលបំណងនៃការកោះសាក្សីទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រហ្នឹងមានអ្វីខ្លះ? សូមឱ្យលោកដាក់នៅថ្ងៃស្អែកព្រឹក ដោយសារថា វគ្គនេះហៀបនឹងចប់ទៅហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការបង្ហាញនូវឯកសារភស្តុតាង ចំពោះមុខភាគី។ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានឯកសារមួយទៀតដែលទាក់ទងទៅនឹងបញ្ហានយោបាយនៃជម្លៀសប្រជាជនដដែល គឺឯកសារដូចតទៅនេះ៖ សារនៃការអបអរសាទររបស់លោក ខៀវ សំផន ចុះថ្ងៃទី ២២ មេសា ឆ្នាំ១៩៧៥។ ឯកសារនេះមានលេខយោង D359/1.1.37 ERN ជាភាសាបារាំង 005374518 រហូតដល់ 81 លេខចុងកន្ទុយ។ ឯកសារនេះកំពុងតែបកប្រែជាភាសាខ្មែរ និងជាភាសាអង់គ្លេស។ អ៊ីចឹងខ្ញុំសូមបញ្ជាក់ថា សារអបអរសាទររបស់លោក ខៀវ សំផន នេះមាននៅក្នុងឯកសារមួយទៀត ដែលមាន ដែលលេខ E3/118 គឺជាសម្រង់ឯកសារ គឺជាសេចក្តីថ្លែងការណ៍តាមវិទ្យុ ដែលបានថតដោយ អេហ្វ.ប៊ី.អាយ.អេស-- *ហ្វ័រវិន ប្រតខាស៊ីរ*-- លេខ ERN ជាភាសាអង់គ្លេសមានដូចតទៅនេះ គឺថា 00166994 រហូតដល់ 96 លេខ ERN ជាភាសាខ្មែរ 0072266 រហូតដល់ 88 លេខចុងកន្ទុយ។

[១០:៥៨:៤៨]

នេះគឺជាសារអបអរសាទរនៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥ គឺថាបន្ទាប់ពីការដួលរលំរបបភ្នំពេញ។ "អ៊ិល" គឺបានសំដៅលើការជោគជ័យរបស់កងទ័ពបដវិត្តន៍កម្ពុជា ក្រោមមាគ៌ាដ៏ភ្លឺស្វាង ដែលរបស់ប្រជាជនយើង គឺកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា នៅក្នុងការដឹកនាំសង្គ្រាមប្រជាជនដ៏មហាខ្លាំងក្លា ហើយនិងពុះកញ្ជ្រោល ដែលវាយប្រហារសត្រូវគ្រប់វិស័យទាំងអស់ គឺវិស័យយោធា នយោបាយ សេដ្ឋកិច្ច ហើយនិងតាមទស្សនវិស័យនៃការជម្លៀសប្រជាជនចេញពីមូលដ្ឋានដែលស្ថិតនៅក្រោមការ

គ្រប់គ្រងបណ្ដោះអាសន្នរបស់សត្រូវ។ ហើយយើងធ្វើឲ្យសត្រូវចាញ់ជាបន្តបន្ទាប់ ហើយនិងឲ្យសត្រូវបាត់កម្លាំងយោធា នយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្បៀង គឺថារហូតដល់តែអស់រលីងតែម្ដង។ រហូតដល់ថ្ងៃថាស្លាប់ជាបន្តិចម្ដងៗ និងស្លាប់ដាច់ខ្យល់តែម្ដង។ ខ្ញុំមិនដឹងថា ជនជាប់ចោទណាមួយចង់ឆ្លើយតបទៅនឹងវគ្គនេះទេ ដែលថាជាវគ្គដ៏គួរឲ្យចាប់អារម្មណ៍ ទាក់ទងទៅនឹងមាគ៌ារបស់កងទ័ពបដិវត្តន៍ប្រជាជន-- រំដោះជាតិកម្ពុជា។ ជាពិសេសគឺទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សត្រូវ។ តើជនជាប់ចោទណាមួយ នួន ជា, ខៀវ សំផន ចង់ឆ្លើយតបទៅនឹងវគ្គដែលខ្ញុំទើបនឹងអាននេះទេ?

[១១:០១:២៨]

តើលោកបានឮខ្ញុំនិយាយដែរឬទេ?

អ៊ីចឹង តើយើងត្រូវចាត់ទុកថា ភាពស្ងៀមស្ងាត់របស់លោកនេះ ចាត់-- ត្រូវចាត់ទុកថា ដែលថាលោករក្សាសិទ្ធិមិនឆ្លើយតបដែរឬទេ? ឬក៏លោកថាមិនមានពាក្យពេចន៍អ្វីដែលត្រូវនិយាយតែប៉ុណ្ណោះ?

អ៊ីចឹង ខ្ញុំគិតថាយើងចូលទៅឯកសារថ្មីមួយទៀត គឺជាឯកសារមួយចំនួនដែលទាក់ទងទៅនឹងកម្មវិធីនយោបាយ ហើយនិងសមាសភាពនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ បាទ ជាបឋម គឺយើងនិយាយអំពីឯកសារដែល IS18.1 ឯកសារមានចំណងជើងថា អាសនៈកម្ពុជានៅអង្គការសហប្រជាជាតិ លេខយោង ERN ជាភាសាបារាំង និងជាភាសាអង់គ្លេស គឺថាមានលេខដូចគ្នា ព្រោះថាវាឯកសារនេះមានជាពីរភាសាតែម្ដង គឺថា 00068101 ទៅដល់ 126 ចុងកន្ទុយ 29 នៅចុងកន្ទុយ។ ទំព័រ១១ និង ១២ ជាភាសាបារាំង ហើយនិង ២៥-២៦ ជាភាសាអង់គ្លេស។ ERN ជាភាសាខ្មែរគឺ 00290197 ហើយនិង 00 រហូតដល់198 នៅចុងកន្ទុយ។ មាន យើងនឹងមានការបកប្រែបន្ថែមទៀត ព្រោះថាអត្ថបទនេះត្រូវបានបកប្រែជា-- ដោយតែផ្នែកមួយតែប៉ុណ្ណោះ ហើយខ្ញុំដឹងឯកសារនេះមាននៅក្នុងសំណុំរឿងហើយ។

[១១:០៤:០៩]

គឺជាកម្មវិធីនយោបាយរបស់ ហ្វ៊ុង ដែលចុះថ្ងៃទី១៨ មិថុនា ឆ្នាំ១៩៧៦ ដែលនៅក្នុងឱកាសទស្សនកិច្ចរបស់ ហ្រ្គុង នៅទីក្រុងញូវយ៉ក ដើម្បីធ្វើការបង្ហាញថាខ្លួនជាអ្នកតំណាងស្របច្បាប់នៃប្រទេសកម្ពុជា។ ដូច្នេះ គឺអ៊ីចឹងជាការសមស្របក្នុងការផ្ដល់អាសនៈមកដល់ប្រទេសកម្ពុជា ទៅដល់ខ្លួន។ បាទ ខ្ញុំអានវែងបន្តិច "រាជរដ្ឋាភិបាលរួបរួមជាតិនៃកម្ពុជា ដើរតាមនយោបាយដែលមាគ៌ា ដែល

មានបង្ហាញនៅក្នុងកម្មវិធីនយោបាយរបស់ ហ្វុង ដែលមានធានានូវប្រជាធិបតេយ្យ និងការបញ្ចេញមតិ និងជំនឿ ការគោរពកម្មសិទ្ធិ សិទ្ធិលើកម្មសិទ្ធិឯកជន ហើយនយោបាយក្រៅប្រទេសគឺអព្យាក្រឹតហើយពុំចូលបក្សសម្ព័ន្ធ។ រដ្ឋាភិបាលមានកូនចៅទៅជាប្រទេសកម្ពុជា ដែលល្បីឈ្មោះក្នុងការដែលខ្លួនស្មោះត្រង់នឹងប្រជាជន ហើយនិងមានចំណេះដឹងរឹងមាំ ហើយនិងមានបទពិសោធន៍ក្នុងការគ្រប់គ្រងកិច្ចការរដ្ឋ។ នៅមុននឹងការរដ្ឋប្រហារនៅថ្ងៃទី១៨ មីនា ថាពួកគាត់មានតំណែងខ្ពស់ខ្ពស់ដូចជា១ប្រធានគណៈរដ្ឋមន្ត្រី សភាជាតិជាដើម គឺថាមានរដ្ឋមន្ត្រីចំនួន១១ ហើយនិង--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យលោកចៅក្រម អានយឺតបន្តិចពីព្រោះអ្នកបកប្រែបកអត់ទាន់។

**ប្រធានអង្គជំនុំ៖**

លោក ហ្សង់ម៉ាក អានឲ្យយឺតជាងនេះ ហើយអានត្រឡប់ក្រោយបន្តិចមកវិញ ហើយអានយឺតដើម្បីឲ្យអ្នកបកប្រែអាចបកទាន់ ព្រោះបើអ្នកបកប្រែ បកអត់ទាន់ទេ។

[១១:០៦:៤៧]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ ខ្ញុំនឹងអានឡើងវិញ ប៉ុន្តែមិនចាប់ផ្តើមពីដំបូងទេ។

គឺចាប់ពីរដ្ឋាភិបាលហ្នឹង នេះគឺថាមានកូនស្រីកូនប្រុសរបស់កម្ពុជាដែលទទួលស្គាល់ថា មានស្មារតីស្នេហាជាតិ ហើយនិងការភក្តីចំពោះបុព្វហេតុនៃប្រជាជន។ ហើយភាគច្រើនគឺមានចំណេះដឹងរឹងមាំ ហើយនិងបទពិសោធន៍ទូលំទូលាយក្នុងការគ្រប់គ្រងកិច្ចការរដ្ឋ ដើម្បីនឹងទទួលការកាន់កាប់កិច្ចនេះមុននឹងការរួមគំនិតក្បត់នៅថ្ងៃ១៨ មីនា ឆ្នាំ៧០ ដើម្បីទទួលនូវការទំនួលខុសត្រូវសំខាន់ៗ គឺជាឧទាហរណ៍ ដូចជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រី តំណាងរាស្ត្រ ឯកអគ្គរដ្ឋទូត...។ល។

[១១:០៧:៣៥]

រដ្ឋមន្ត្រី និងអនុរដ្ឋមន្ត្រី ១១នាក់ ដែលជាអ្នកកាន់ក្រសួងសំខាន់ៗដូចជា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន និងឃោសនាការ គឺពួកគាត់ទាំងអស់នេះ គឺថាបំពេញតួនាទីនៅក្នុងប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ធ្វើការត្រួតត្រាទៅលើទឹកដីជាតិ ៩០ភាគរយដែលជាតំបន់រំដោះ និងដឹកនាំការតស៊ូរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ដែលត្រូវបានត្រួតត្រាជាបណ្តោះអាសន្នដោយក្រុមក្បត់នៅទីក្រុងភ្នំពេញ។

នៅទីនេះ គឺថាពួកគេមានអំណាចពិតប្រាកដតាមរយៈការរៀបចំរដ្ឋបាលដែលត្រូវបានរៀបចំរចនាសម្ព័ន្ធជាត្រឹម-- យ៉ាងត្រឹមត្រូវនៅក្នុងគ្រប់ថ្នាក់ទាំងអស់ដូចជា ថ្នាក់ភូមិ ថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ខេត្ត។ នៅទីនោះ គឺមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ប្រជាជនមានសិទ្ធិជ្រើសរើសតំណាងរបស់ខ្លួនដើម្បីចូលរួមនៅក្នុងការគ្រប់គ្រងកិច្ចការសាធារណៈនៅគ្រប់ជាន់ថ្នាក់”។

[១១:០៩:០០]

**ស៖** លោក នួន ជា តើលោកមានការអត្ថធិប្បាយអ្វីទៅលើអត្ថបទដែលខ្ញុំបានអាននេះទេ? តើកម្មវិធីនយោបាយដែលចែងអំពីការគោរពសិទ្ធិ និងការគោរពកម្មសិទ្ធិឯកជន សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់ តើជាកម្មវិធីដែលស្របទៅនឹងមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? ហើយតើវាស្របទៅនឹងវិធានការដែលអនុវត្តនៅឆ្នាំ៧៣ នៅក្នុងតំបន់រំដោះដែរឬទេ?

**លោក នួន ជា៖**

**ឆ៖** គោរពលោកប្រធាន ខាងផ្នែករដ្ឋបាលខ្ញុំមិនដឹងទេ។ ព្រោះខ្ញុំដាច់ខាងបក្ស ខ្ញុំអប់រំ។

[១១:១០:០៩]

**ស៖** លោក នួន ជា តើលោកអាចជម្រាបយើងបានទេ ថាតើការអប់រំរបស់លោកហ្នឹង លោកបានបង្រៀនទៅនឹងសិទ្ធិរបស់-- ទាក់ទងនឹងសិទ្ធិសេរីភាព គឺថាសេរីភាពក្នុងការបញ្ចេញមតិ ទាក់ទងនឹងកម្មសិទ្ធិឯកជនអីជាដើមនោះ?

**ឆ៖** សូមគោរពលោកប្រធាន ការអប់រំរបស់បក្ស សំដៅកម្ចាត់ធាតុបុគ្គលនិយម អាជ្ញានិយម ពុករលួយ កសាងគោលជំហរស្នេហាជាតិ ស្នេហាប្រជាជន ស្នេហាបក្ស។ តស៊ូដាច់ខាត លះបង់ផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីផលប្រយោជនរួម កាលណាជំទាស់ផលប្រយោជនផ្ទាល់ខ្លួននឹងរួម ជំទាស់គ្នាត្រូវគិតផលប្រយោជន៍រួមមុន។ នេះគោលការណ៍មួយចំនួនធំរបស់បក្ស។ ខ្ញុំអប់រំតែខាងកម្ចាត់ធាតុបុគ្គលនិយម អានោះវាធំណាស់ អំណាចនិយម លុយកាក់និយម ពុក-- ន៎ែ ស្រីស្រាបៀរប៉ោ និយាយរួមឧបាយមុខគ្រប់បែបយ៉ាង ហើយនិងខាងសតិអារម្មណ៍។ ឯការវិធីអប់រំនោះ វាមានច្រើនទៅទៀត។ ខ្ញុំសូមជម្រាបដោយខ្លីប៉ុណ្ណឹង។

**ស៖** លោក នួន ជា តើការបំបាត់បុគ្គលនិយមនោះ វាស៊ីគ្នានឹងការគោរពសិទ្ធិកម្មសិទ្ធិឯកជន និងសិទ្ធិសេរីភាពរបស់បុគ្គលដែរឬទេ?

[១១:១២:១៩]

**ឆ៖** គោរពលោកប្រធាន កុំយល់ខុស។ កម្ចាត់បុគ្គលនិយម គឺកម្ចាត់ធាតុអាត្មានិយម គិតតែផលប្រយោជន៍ផ្ទាល់ខ្លួន មិនគិតផលប្រយោជន៍រួម គិតតែពីអំណាច អាជ្ញា ដូចខ្ញុំបានជម្រាបអ៊ីចឹង។ មិនគោរពមាគ៌ានយោបាយរបស់បក្ស ច្រើនណាស់ បើឱ្យនិយាយ សេរីនិយម ស្រីស្រា លុយកាក់។ អាហ្នឹងសរុបមក បានហៅបុគ្គលនិយម ឬបើតាមភាសាបាលី ភាសាព្រះ "កម្ចាត់នូវសកាយទិដ្ឋិ"។

**ស៖** បាទ ខ្ញុំចោទសំណួរនេះ បែបផ្សេងវិញ លោក នួន ជា។ តើការគោរពសិទ្ធិកម្មសិទ្ធិឯកជននេះ ជាតម្លៃមួយដែលលោកបង្រៀនដល់សិស្សរបស់លោកដែរឬទេ?

**ឆ៖** លោកគោរពលោកប្រធាន អប់រំវាមានច្រើន គោរពនូវកម្មសិទ្ធិឯកជន គោរពកម្មសិទ្ធិអី? មិនមែនកម្មសិទ្ធិខាងដីធ្លី ទ្រព្យសម្បត្តិអីទេ។ គោរពសិទ្ធិក្នុងការមានមតិ គោរពសិទ្ធិសេរីភាពខាងការនិយាយស្តី ស្នើមតិ ប្រឆាំងទំនាស់ៗមតិ។ អានេះ ជាមូលដ្ឋាន។

[១១:១៥:០៦]

**ស៖** នៅពេលដែលខ្ញុំអានពាក្យថា មានលទ្ធិប្រជាធិបតេយ្យមួយ ហើយប្រជាជនបានជ្រើសរើសអ្នកតំណាងរបស់ខ្លួនដើម្បីចូលរួមក្នុងការគ្រប់គ្រងកិច្ចការសាធារណៈ និងគ្រប់កម្រិតថ្នាក់ទាំងអស់។ លោកដែលអាចអ្នកផ្តល់ការបណ្តុះបណ្តាលនោះ តើពាក្យថា លទ្ធិប្រជាធិបតេយ្យពិតប្រាកដនេះមានន័យយ៉ាងម៉េចដែរ?

**ឆ៖** គោរពលោកប្រធាន លទ្ធិប្រជាធិបតេយ្យ គឺប្រជាធិបតេយ្យប្រមូលផ្តុំ។ ទាំងអស់គ្នាឧបមាថា ឧបមា ខ្ញុំឧបមាចុះ មិនមែនជាភាគដែលតិច ថាភាគច្រើនជាធំទេ។ គឺឧបមា៥០ ទល់នឹង៤៩ ចុះ៤៩នោះវាចោលទទេទៅ។ ត្រូវរក្សាទុក អានេះលទ្ធិប្រជាធិបតេយ្យ ខាងមតិខាងប្រជាធិបតេយ្យ ពួកខាងខ្ញុំ ខាងនៃ បក្សកុម្មុយនីស្តកម្ពុជា។

**ស៖** លោក នួន ជា បើតាមលោក គឺថាមាគ៌ានយោបាយដែលមាននៅក្នុងឯកសារ នៅអង្គការសហប្រជាជាតិ នៅឆ្នាំ១៩៧៣នោះ គឺថាសមស្របជាមួយនឹងមាគ៌ានយោបាយនៃបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? ឬក៏នៅសម័យនោះ គឺថាសមស្រប និងមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនដែលឃើញឯកសារហ្នឹងផង។

[១១:១៧:៣៨]

**ស៖** តើលោកបានព្យាយាម ស្គាល់អំពីមាគ៌ានយោបាយរបស់ ហ្រ្គុង ឬក៏ជាបញ្ហាមួយដែលលោកមិនចាប់អារម្មណ៍ទាល់តែសោះ?

**ឆ៖** គោរពលោកប្រធាន ហ្វុង ហ្វ្រុងហ្នឹង ខាងរដ្ឋបាល ហើយខ្ញុំខាងបក្ស។ ឮៗនិយាយ ប៉ុន្តែឲ្យទៅសុំចូលជ្រៅ ក៏មិនចូលជ្រៅដែរ ព្រោះខ្ញុំគិតតែខាងអប់រំ ទស្សនៈ គោលជំហររបស់បក្សយ៉ាង ម៉េច អីយ៉ាងម៉េច។

**ស៖** ចំពោះលោកនៅក្នុងតំបន់រំដោះនោះ តើអ្នកណាជាអ្នកកាន់អំណាចដោយពិតប្រាកដនោះ តើជាហ្វ្រុង ឬក៏ជាហ្វុង ឬក៏ជាអ្នកតំណាងបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** គោរពលោកប្រធាន បើខាងរដ្ឋបាលទៅខាងរដ្ឋបាល បើខាងបក្ស ខាងបក្ស។ ដោយសារបក្សណែនាំ បក្សដឹកនាំ។

**ស៖** ចុះចំពោះកងទ័ពវិញ តើអ្នកណាជាអ្នកគ្រប់គ្រងកងទ័ព?

**ឆ៖** គោរពលោកប្រធាន ខ្ញុំដឹងមិនច្បាស់ទេ ប៉ុន្តែខាងកងទ័ពមានគណៈកម្មាធិការកងទ័ព ប៉ុល ពត មេបញ្ជាការកងទ័ព។

[១១:២០:០៧]

**ស៖** ចុះលោក តើលោកជាសមាជិកនៃគណៈកម្មការនុ៎ងដែរឬទេ?

**ឆ៖** ខ្ញុំអត់ធ្វើសមាជិកគណៈកម្មការកងទ័ពទេ គោរពលោកប្រធាន។

**ស៖** តើលោកដឹងទេថា លោក ខៀវ សំផន កាន់កាប់មុខងារជាឧបនាយករដ្ឋមន្ត្រី ហើយនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិនៅពេលនោះ លោកដឹងដែរឬទេ?

**ឆ៖** ខ្ញុំឮ ប៉ុន្តែឲ្យខ្ញុំដឹងការងារគាត់ម៉េចៗ ខ្ញុំមិនដឹងទេ។

**ស៖** បើឥឡូវខ្ញុំផ្តល់ជាព័ត៌មានដល់លោក តើលោកប្រហែលជាមិនស្គាល់ *ហ្វ្រុន* ទេ? អ៊ីចឹងខ្ញុំសូមអានឯកសារមួយដោយមាននៅក្នុងឧបសម្ព័ន្ធ ដែលឯកសារដែលខ្ញុំនឹងលើកឡើងហ្នឹង ដែលទាក់ទងនឹងសមាសភាពរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ រដ្ឋមន្ត្រី-- នាយករដ្ឋមន្ត្រី គឺលោក ប៉ែន នុត ឧបនាយករដ្ឋមន្ត្រី ហើយនិងរដ្ឋមន្ត្រីក្រសួងការពារជាតិ គឺលោក ខៀវ សំផន។ ហើយលោក សារិន ឆាក រដ្ឋមន្ត្រីក្រសួងការបរទេស។ តើលោកដឹងថា លោក សារិន ឆាក ហ្នឹងក្លាយជាអីដែរឬទេ នៅរបបកម្ពុជាប្រជាធិបតេយ្យនុ៎ង?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនស្គាល់ផង។

**ស៖** លោក ហ៊ូ យន់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលបន្ទុកក្នុងការរៀបចំជនបទ និងសហករណ៍។ តើលោកស្គាល់លោក ហ៊ូ យន់ ដែរឬទេ? តើលោកដឹងថា មានរឿងអ្វីកើតឡើងចំពោះ

គាត់ដែរឬទេនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ជម្រាបលោកប្រធាន ខ្ញុំស្គាល់ ប៉ុន្តែមិនជិតស្និទ្ធ។ ការងារផ្សេងគ្នា។

**ស៖** តើលោក មានរឿងអីកើតឡើងដល់លោក ហ៊ូ យន់ នៅក្រោមរបបកម្ពុជាប្រជាធិប-តេយ្យនោះ?

**ឆ៖** តាមខ្ញុំឮ មានការជំទាស់គ្នាជាមួយកងការពារគាត់។

**ស៖** ហើយកាលនោះមានរឿងអីកើតឡើង?

**ឆ៖** តាមខ្ញុំឮ គឺថាមានការបាញ់គ្នា ហើយកងការពារគាត់ជនជាតិភាគតិច រត់បាត់ទៅ។

**ស៖** អ៊ីចឹង លទ្ធផលនៃការជម្លោះហ្នឹង កើតចេញទៅជាស្អីទៅ?

**ឆ៖** ជម្រាបលោកប្រធាន ខ្ញុំមិនបានតាមដានរឿងហ្នឹងទេ ព្រោះមិនមែនរឿងរបស់ខ្ញុំ ខាងរដ្ឋបាល។

[១១:២៥:០០]

**ស៖** បើខ្ញុំ-- លោក នួន ជា ខ្ញុំមិនយល់ទេ ហេតុអីបានថាជម្លោះរវាងលោក ហ៊ូ យន់ ហើយនិងអង្គរក្សរបស់ខ្លួននោះពាក់ព័ន្ធទៅនឹងរឿងរដ្ឋបាលទៅវិញ។ តើលោក ហ៊ូ យន់ គាត់ស្លាប់នៅក្នុងពេលជម្លោះនោះ ឬក៏យ៉ាងម៉េច?

**ឆ៖** បញ្ហានេះខ្ញុំមិនដឹងទេ ដឹង-- ឮតែរាយការណ៍។ ឮថាទំនាស់គ្នា ហើយកងការពារគាត់បាញ់គាត់ទៅ។

**ស៖** តើគាត់ស្លាប់ ឬក៏មិនស្លាប់ទេនៅពេលនោះ?

**ឆ៖** ខ្ញុំមិនដឹងដែរ ជម្រាបលោកប្រធាន ពីព្រោះនេះខាងរដ្ឋបាលគេដឹង គេរាយការណ៍-- ឯឲ្យល្អិត ខ្ញុំមិនដឹងទេ គ្រាន់ដឹងរួមៗ។

**ស៖** សមាជិករដ្ឋាភិបាលមួយទៀតគឺលោក ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការ។ តើលោកស្គាល់លោក ហ៊ូ នឹម ទេ? ហើយលោកដឹងថាមានរឿងអ្វីកើតឡើងចំពោះលោក ហ៊ូ នឹម ដែរឬទេ?

**ឆ៖** គោរពលោកប្រធានខ្ញុំស្គាល់ ប៉ុន្តែខ្ញុំមិនដឹងមានរឿងកើតអី។

**ស៖** លោក ថៅ សេង រដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស។ តើលោកស្គាល់លោក ថៅ សេង ដែរឬទេ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនដែលស្គាល់ទេ ឮតែឈ្មោះ។

**ស៖** តើលោកដឹងថា មានរឿងអីកើតឡើងចំពោះគាត់ដែរឬទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនដឹងទេ។

**ស៖** លោក ចាន់ យូរ៉ាន់ រដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងយុវជន។ លោក ង៉ោ ហ៊ូ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងកិច្ចការសាសនា និងសង្គមកិច្ច។ លោក ជួន មុំ តើលោកស្គាល់លោក ជួន មុំ ដែរឬទេ គាត់ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ?

**ឆ៖** ខ្ញុំឮឈ្មោះ គោរពលោកប្រធាន ប៉ុន្តែខ្ញុំមិនដែលស្គាល់គាត់ជិតស្និទ្ធទេ ព្រោះខាងផ្នែករដ្ឋបាល។

[១១:២៨:៤៦]

**ស៖** ឧត្តមសេនីយ៍ ដួង សំអុល ដែលជារដ្ឋមន្ត្រីទទួលបន្ទុកភស្តុភារ យោធា និងគ្រឿងសព្វាវុធ។ លោកស្គាល់គាត់ដែរឬទេ?

**ឆ៖** ជម្រាប គោរពលោកប្រធាន ខ្ញុំមិនដែលស្គាល់សុទ្ធ។

**ស៖** លោក ហួត សម្បត្តិ រដ្ឋមន្ត្រីក្រសួងសាធារណការ និងទូរគមនាគមន៍និងសាងសង់ តើលោកដឹងទេថា មានរឿងអីកើតឡើងដល់លោក ហួត សម្បត្តិ ដែរឬទេ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំអត់ដឹងទេ។

[១១:២៩:៤៤]

**ស៖** លោក ជា សាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងកំណែទម្រង់តុលាការ។ តើលោកស្គាល់លោក ជា សាន ដែរឬទេ?

**ឆ៖** គោរពលោកប្រធាន កាន់តែមិនដែលស្គាល់ទៀតហើយ មិនដែលឮឈ្មោះផង។

**ស៖** ហើយលោក គាត ឈន់ ដែលជារដ្ឋមន្ត្រីស្ដីទីនៃគណៈរដ្ឋមន្ត្រី តើលោកស្គាល់ដែរឬទេ លោកគាត ឈន់?

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំស្គាល់ ប៉ុន្តែមិនជិតស្និទ្ធ មិនដែលនិយាយគ្នាផង ប៉ុន្តែស្គាល់មុខ។

**ស៖** លោកជួន ប្រសិទ្ធិ រដ្ឋមន្ត្រីទទួលបន្ទុកសម្របសម្រួលការខិតខំប្រឹងប្រែងតស៊ូរំដោះជាតិ តើលោកស្គាល់លោក ជួន ប្រាសិទ្ធ ដែរឬទេ?

[១១:៣០:៤៩]

**ឆ៖** គោរពលោកប្រធាន ខ្ញុំស្គាល់ ប៉ុន្តែមិនដែលជានិយាយគ្នាទេ មិនដែលធ្វើការអីជាមួយគ្នាទេ។

**ស៖** ព្រះអង្គម្ចាស់សម្តេចនរោត្តម ភូរីស្សា ដែលជារដ្ឋមន្ត្រីកិត្តិយស--

**ឆ៖** គោរពលោកប្រធាន--

**អ្នកបកប្រែ៖** (សូមកែប្រែលោក-- សម្តេច នរោត្តម ភូរិស្សរា)។

**ឆ៖** គោរពលោកប្រធាន ខ្ញុំឮឈ្មោះ ប៉ុន្តែមិនដែលស្គាល់ទេ មិនដែលឃើញរូបផង។

**ស៖** លោក គង់ សុផល អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ តើលោកស្គាល់គាត់ដែរឬទេ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនដែលស្គាល់ទេ។

[១១:៣១:៥៨]

**ស៖** លោក ប៉ុក ដឹសកុមារ អនុរដ្ឋមន្ត្រីក្រសួងការបរទេស តើលោកធ្លាប់ស្គាល់គាត់ដែរឬទេ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំធ្លាប់ស្គាល់ ប៉ុន្តែមិនសូវនិយាយគ្នាទេ។ ការងារខុសគ្នា។

**ស៖** លោក វ៉ាន់ ពិនី អនុរដ្ឋមន្ត្រីក្រសួងការបរទេស។ តើលោកដឹងថាមានរឿងអ្វីកើតឡើងដល់លោក វ៉ាន់ ពិនី ដែរឬទេ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនដែលដឹងទេ។ ដូចខ្ញុំជម្រាបហើយ គឺថាខាងរដ្ឋាភិបាលខ្ញុំមិនដឹងទេ។ បើគេឲ្យដឹង ដឹងទៅ បើគេមិនឲ្យដឹងហីទៅ។ ព្រោះខាងខ្ញុំជម្រាបអ៊ីចេះ គោលការណ៍ក្នុងបក្សការងារនរណា អ្នកនោះដឹង។ ហើយកុំទៅជជីកទៅសួរគេនោះ ការងារយើង យើងដឹង។ ការងារគេ គេដឹង គេធ្វើខ្លួនគេ។ អានេះគោលការណ៍វាមានអ៊ីចឹងតាំងពីដើមមក។

**ស៖** លោក សុខ ធួក អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលបន្ទុករៀបចំជនបទ និងសហករណ៍ តើលោកស្គាល់គាត់ទេ?

[១១:៣៣:៥០]

**ឆ៖** ខ្ញុំមិនដែលស្គាល់ទេ។ គោរពលោកប្រធាន។

**ស៖** លោក ទីវ អុល អនុរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការ លោកស្គាល់គាត់ទេ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំស្គាល់ ប៉ុន្តែមិនជិតស្និទ្ធទេ ព្រោះគេខាងរដ្ឋបាល។

**ស៖** លោក នួន ជា តើលោកអាចដឹងទេថា តើមានកើតអីរឿងអីកើតឡើងចំពោះលោក ទីវ អុល ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំមិនដឹងទេ ព្រោះបែកគ្នាមកយូរហើយ។

[១១:៣៥:០០]

**ស៖** អ្នកខាងមុខនេះ គឺលោកប្រហែលជាស្គាល់ហើយ គឺជាលោកស្រី អៀង ធីរិទ្ធ អនុរដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងយុវជន។ តើយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំស្គាល់ គោរពលោកប្រធាន ខ្ញុំស្គាល់។

**ស៖** បន្ទាប់មកគឺលោក ជូ ជេត អនុរដ្ឋមន្ត្រីក្រសួងសុខាភិបាលកិច្ចការសាសនា និងសង្គមកិច្ច តើលោកដឹងទេថា មានរឿងអីកើតចំពោះលោក ជូ ជេត នៅសម័យកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំស្គាល់ ប៉ុន្តែមានរឿងអីកើតឡើង ខ្ញុំមិនដឹងទេ។

**ស៖** ជាចុងក្រោយនៅក្នុងបញ្ជីឈ្មោះនេះ គឺលោក កុយ ធួន អនុរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តើលោកស្គាល់លោក កុយ ធួន ដែរឬទេ?

**ឆ៖** គោរពលោកប្រធាន ខ្ញុំស្គាល់។

**ស៖** តើលោកដឹងទេថាអាចមានរឿងអីកើតឡើងចំពោះលោក កុយ ធួន នៅសម័យកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំមិនបានដឹងផ្ទាល់ទេ ប៉ុន្តែគេប្រាប់ គឺរឿងគាត់-- រឿងស្រីញី រឿងកាប់សម្លាប់គូសង្សារម្នាក់នោះ។

**ស៖** តើគេសម្លាប់គាត់នៅកន្លែងណា?

**ឆ៖** ខ្ញុំមិនដែលដឹង ខ្ញុំមិនដឹងទេ។

[១១:៣៧:១៤]

**ស៖** ខ្ញុំសូមបញ្ជាក់ថា បញ្ជីឈ្មោះនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានេះ គឺមានការផ្លាស់ប្តូរជាច្រើន ហើយមានការកែប្រែសមាសភាពជាច្រើនលើកច្រើនសា ខ្ញុំប្រហែលជាមិនអាចជម្រាបជូននៅថ្ងៃនេះបានទេ។ ខ្ញុំមិនដឹងថា តើលោក ខៀវ សំផន ឬក៏លោក អៀង សារី ពីព្រោះលោក អៀង សារី គាត់អាចស្តាប់ពីមន្ទីរឃុំឃាំងបាន ថាតើអ្នកទាំងពីរនេះចង់មានការឆ្លើយតបទៅលើការអានឯកសារ

បញ្ជីឈ្មោះនេះដែរឬទេ ឬក៏គាត់ចង់ផ្ដល់សេចក្ដីសង្កេតអីទៅលើឯកសារនេះ? ព្រោះថាគាត់អាចមានបញ្ហាខាងការចងចាំ ឬក៏គាត់អាចចងចាំឈ្មោះអ្នកទាំងអស់គ្នា ឬក៏យ៉ាងណាដែរ សូមឲ្យខាងជនជាប់ចោទបញ្ជាក់។

[១១:៣៨:០០]

**លោក ខៀវ សំផន៖**

សូមគោរពអង្គជំនុំជម្រះ។ ខ្ញុំមិនមានស្អីអត្ថាធិប្បាយទេនៅពេលនេះ។ បាទសូមអរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

យើងនឹងបន្តទៅទៀតជាមួយនឹងឯកសារមួយទៀត គឺឯកសារD108/43/3។ វាគឺជាលិខិតចុះថ្ងៃទី២០ មីនា ៧៥ ដែលផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិដោយតំណាងអចិន្ត្រៃយ៍នៃបារាំងប្រចាំនៅអង្គការសហប្រជាជាតិ-- នៅប្រទេសចិន (សូមទោស)។ ហើយជាទូរលេខរបស់លោក សារិន ឆាក រដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលកម្ពុជាស្នើសុំឲ្យ-- សេចក្ដីថ្លែងការណ៍នៅក្នុងទូរលេខនេះត្រូវបានផ្ដល់ជូន ហើយនិងចែកចាយទៅឲ្យរដ្ឋនៃសមាជិកអង្គការសហប្រជាជាតិទាំងអស់។ នេះគឺជាសេចក្ដីប្រកាសដែលបានចុះផ្សាយដោយមហាសន្និបាតកម្ពុជាលើកទីពីរដែលបានប្រព្រឹត្តនៅថ្ងៃទី២៤-២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ក្រោមអធិបតីភាពលោក ខៀវ សំផន។

[១១:៣៩:៤៣]

នេះគឺជាឯកសារវែងគួរសមដែរ ខ្ញុំនឹងមិនអានទេ ខ្ញុំគ្រាន់តែព្យាយាមសង្ខេបក្នុងឯកសារនោះ គឺបាននិយាយដូចតទៅនេះ គឺជាសេចក្ដីថ្លែងការណ៍ដែលត្រូវបានអនុម័តដោយឯកច្ឆន្ទនៃអ្នកចូលរួមក្នុងមហាសន្និបាត ហើយមានសមាសភាពរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិ មានតំណាងអង្គការមហាជន តំណាងសមាគមស្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ តំណាងសមាគមកសិករ និងសហជីព តំណាងសមាគមព្រះសង្ឃស្នេហាជាតិ សមាគមបញ្ញវន្តស្នេហាជាតិ សមាគមអ្នកនិពន្ធ ហើយនិងអ្នកករីស្នេហាជាតិ តំណាងកងទ័ពទាំងបីនៃកងទ័ពរំដោះប្រជាជនជាតិកម្ពុជា។ ហើយសេចក្ដីប្រកាសនេះ គឺនិយាយអំពីចំណុចប្រាំបីពាក់ព័ន្ធទៅនឹងមាគ៌នយោបាយក្រៅប្រទេស និងក្នុងប្រទេស របស់រាជរដ្ឋាភិបាលរួបរួមជាតិ។

ចំណុចទី១ មហាជនក្បត់ទាំងប្រាំពីរ ដូចជា លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, ចេង ហេង អ៊ិន តាំ, ឡុង បូរ៉េត និង ស្វស្តែន ហ្វែកណាង់ដេស ត្រូវបានកាត់ទោសប្រហារជីវិត។ មន្ត្រីរដ្ឋការ

មេទាហាន និងកងទ័ព ហើយនិងនាយនគរបាលទាំងអស់ អ្នកខាងផ្នែកការពារជាតិ អ្នកនយោបាយ ហើយនិងឥស្សរជនផ្សេងៗទៀត ដែលរស់នៅក្នុងមូលដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងបណ្តោះអាសន្នដោយខ្មាំង ត្រូវបានអញ្ជើញឲ្យបោះបង់ចោលមហាជនក្បត់ទាំងប្រាំពីរ ហើយសូមចូលរួមជាមួយនឹងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដើម្បីមកធ្វើចលនាតស៊ូ។

[១១:៤១:៥៩]

ចំណុចទី២ គឺចង់បានទទួលនូវការជ្រៀតជ្រែក ហើយនិងការឈ្លានពានដោយផ្ទាល់ ឬក៏ដោយប្រយោលរបស់ចក្រពត្តិអាមេរិកប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ ហើយនិងការចាកចេញជាបន្ទាន់នូវទីប្រឹក្សាយោធារបស់អាមេរិក។

ចំណុចទី៣ ពាក់ព័ន្ធទៅនឹងនយោបាយផ្ទៃក្នុង នយោបាយក្នុងប្រទេស ដែលមានបញ្ជាក់ថា គឺមានការធ្វើនយោបាយរួបរួមជាតិកម្ពុជាទាំងអស់ ដោយមិនមានបែងចែកវណ្ណៈសង្គម មិនគិតអំពីនិន្នាការនយោបាយ ជំនឿ សាសនា ឬអតីតកាលរបស់បុគ្គលម្នាក់ៗ ទាំងអស់លើកលែងតែពួកជនក្បត់ទាំងប្រាំពីរតែប៉ុណ្ណោះ។

ពាក់ព័ន្ធទៅនឹងនយោបាយក្រៅប្រទេស គឺមានការរំឭកអំពីនយោបាយអព្យាក្រឹត ហើយនិងឯករាជ្យភាពដែលជាមាគ៌ានយោបាយដែលត្រូវអនុវត្ត ហើយការបដិសេធមិនទទួលយកមូលដ្ឋានយោធាឈ្លានពានទាំងអស់នៅក្នុងទឹកដីកម្ពុជា។ ការបង្កើតនៅទំនាក់ទំនងការទូតជាមួយនឹងប្រទេសជិតឆ្ងាយទាំងអស់ដោយមិនប្រកាន់របបនយោបាយ និងរបបសង្គម ឲ្យតែបណ្តាប្រទេសទាំងអស់នោះគោរពនូវគោលការណ៍ស្មើភាព គោរពគ្នាទៅវិញទៅមក និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក មិនឈ្លានពានគ្នា មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបបប្រទេសដទៃ។ ហើយក៏មានការបញ្ជាក់ដូចតទៅនេះផងដែរ៖ ជាតិនិងប្រជាជនកម្ពុជានឹងទទួលយករាល់ជំនួយទាំងអស់ពីគ្រប់បណ្តាប្រទេសដែលគ្មានលក្ខខណ្ឌភ្ជាប់មកជាមួយ។

[១១:៤៤:២០]

ចំណុចទី៤ គឺជាការអំពាវនាវឲ្យមានការងើបឡើងបះបោរ សម្រាប់ប្រជាជនទាំងអស់នៅទីក្រុងភ្នំពេញដើម្បីឲ្យផ្តួលរំលំជនក្បត់ ហើយនិងអំពើហិង្សាប្រឆាំងជនក្បត់។

ចំណុចទី៥ បង្ហាញអំពីការអំពាវនាវឲ្យបោះបង់ចោលប្រាក់រៀលដែលចេញឲ្យចាយដោយពួកក្បត់ គឺរបប លន់ នល់ ហើយគឺថាពេលនោះ ប្រាក់រៀលគឺគ្មានតម្លៃទៀតទេ ហើយគឺថាត្រូវបានជំនួស

ដោយប្រាក់រៀល ថ្មីដែលបោះពុម្ពដោយរណសិរ្ស-- រាជរដ្ឋាភិបាលរួបរួមជាតិ ហើយមានការនិយាយថានៅក្នុងតំបន់រំដោះការប្រើប្រាស់ប្រាក់រៀលត្រូវបានលុបចោល ហើយត្រូវបានជំនួសដោយការប្រើប្រាស់ប្រព័ន្ធ ដោះដូរទំនិញគ្នាទៅវិញទៅមក។ ហើយមានការនិយាយតទៀតថា៖ នៅពេលអនាគតប្រព័ន្ធដោះដូរ ទំនិញនឹងបន្តអនុវត្តដូចនៅពេលបច្ចុប្បន្នដែរ ហើយប្រាក់រៀលថ្មីដែលបោះពុម្ពដោយរណសិរ្សរួបរួម ជាតិកម្ពុជានិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នឹងដាក់ឲ្យចរាចរជាបណ្ដើរៗ។ ហើយនៅចុងក្រោយនោះមានព័ត៌មានមួយសម្រាប់អ្នកស្នេហាជាតិទាំងអស់ ហើយនិងគ្រប់ស្រទាប់វណ្ណៈទាំងអស់ដែលនៅទីក្រុងភ្នំពេញ ហើយនិងនៅតាមទីរួមខេត្តផ្សេងទៀតដែលត្រូវបានគ្រប់គ្រងបណ្ដោះអាសន្នដោយខ្មាំង។ គឺព័ត៌មាននេះសម្រាប់ឲ្យអ្នក ស្នេហាជាតិឲ្យបោះបង់ចោលនូវជួរក្បត់ដើម្បីចូលរួមជាមួយតំបន់រំដោះ និងរណសិរ្សរួបរួមជាតិកម្ពុជា។ គឺមានការនិយាយថា កុំគិតអំពីការ បញ្ហាជីវភាពហើយនិងការងារ គឺថាអ្វីៗទាំងអស់នេះ គឺយើងធានាជូនប្រជាជនទាំងអស់ សូមកុំព្រួយបារម្ភ។

[១១:៤៦:៣៩]

ចំណុចទី៦ គឺជាការអំពាវនាវទៅដល់ស្ថានទូត ហើយទីភ្នាក់ងារទាំងអស់ដែលប្រចាំនៅក្នុងរបបពួកក្បត់ដើម្បីឲ្យដកបុគ្គលិក និងគ្រួសាររបស់ពួកគេចេញជាបន្ទាន់ពីទីក្រុងភ្នំពេញ និងតំបន់ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ខ្មាំងជាបណ្ដោះអាសន្ន ដើម្បីចៀសវាងគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ។ រណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាបដិសេធមិនទទួលខុសត្រូវចំពោះគ្រោះថ្នាក់បែបនេះឡើយ។

ចំណុចទី៧ គឺជាការបង្ហាញនូវការដឹងគុណយ៉ាងជ្រាលជ្រៅរបស់រណសិរ្សរួបរួមជាតិកម្ពុជាហើយនិងរាជរដ្ឋាភិបាលកម្ពុជាទៅដល់ប្រជាជននៅលើពិភពលោកដែលបានផ្ដល់នូវការគាំទ្រដល់កម្ពុជាប្រជាធិបតេយ្យក្នុងការតស៊ូរបស់ជាតិ។

[១១:៤៧:៣៩]

ចំណុចទី៨ ជាការអំពាវនាវទៅដល់កងទ័ពប្រជាជនរំដោះជាតិកម្ពុជាទាំងបីផ្នែកឲ្យបង្កើននូវការប្រយុទ្ធតស៊ូ វាយសម្រុកប្រឆាំងនឹងខ្មាំងឲ្យបានខ្លាំងក្លាដើម្បីកម្ទេចខ្មាំង និងរំដោះប្រជាជន និងប្រជាជាតិឲ្យ រួចផុតពីខ្មាំងសត្រូវ។

តើលោកមានការ ចង់មានការឆ្លើយតបអ្វីទេចំពោះអ្វីដែលខ្ញុំបានអាននៅក្នុងឯកសារនេះ?

លោក ខៀវ សំផន តើលោកចង់ឆ្លើយតបទេ?

**លោក ខៀវ សំផន៖**

បាទគ្មានទេបាទ។ គ្មានអត្ថាធិប្បាយអ្វីទាំងអស់នាពេលនេះបាទ។ សូមអរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ប្រសិនបើមិនមានការអត្ថាធិប្បាយអីទេ ខ្ញុំសូមចូលទៅឯកសារផ្សេងទៀតដែលមានភាព ពាក់ព័ន្ធនៅក្នុងដំណាក់កាលនេះ។ សូមៗអភ័យទោសសូមកែប្រែ គឺថាខ្ញុំមិនមានឯកសារអ្វីផ្សេងទៀតទេ។

[១១:៤៩:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥២:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ កិច្ចដំណើរការសវនាការពិភាក្សាដេញដោលចំពោះលោក នួន ជា ចំពោះបរិបទអង្គហេតុពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ឃើញថាបានចប់សព្វគ្រប់ហើយ ហើយតាមគម្រោងផែនការ កាលបរិច្ឆេទសម្រាប់កំណត់ធ្វើសវនាការ គឺនៅរសៀលនេះយើងដាក់នូវឯកសារចំពោះមុខភាគី។ ប៉ុន្តែដោយការមិនប្រើប្រាស់ពេលវេលាក្នុងការសួរ ចំពោះកូនក្ដីរបស់ខ្លួន ដោយក្រុមមេធាវី នួន ជា នោះ អង្គជំនុំជម្រះបានចាត់ចែងនូវពេលវេលាព្រឹកមិញ ក្នុងការដាក់នូវឯកសារភស្តុតាងចំពោះមុខភាគីដោយចៅក្រម ហ្សង់ម៉ាក រួចហើយ។ ហើយហេតុដូច្នេះ គឺកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះសម្រេចថាផ្អាកត្រឹមនេះ ហើយកិច្ចដំណើរការសវនាការពិនិត្យក្នុងការដាក់ឯកសារចំពោះមុខភាគី ឬក៏ភាគីមានឯកសារណាចង់ដាក់ចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងពេលមុនពេលអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទសម្រាប់សប្ដាហ៍ក្រោយនោះ ក៏អាចធ្វើបានដែរ ដោយអង្គជំនុំជម្រះសម្រេចលើទៅសវនាការបន្តធ្វើនៅព្រឹកថ្ងៃស្អែក។

ដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយនៅរសៀលនេះ អង្គជំនុំជម្រះត្រូវការប្រជុំ ដើម្បីរៀបចំនូវបញ្ហាផ្សេងៗ សំខាន់ៗជាច្រើនទៀត នៅក្នុងការជំរុញកិច្ចដំណើរការសវនាការដេញដោលនៅក្នុងសំណុំរឿងនេះសម្រាប់វគ្គក្រោយៗទៀត។ ហើយសូមអង្គភាគីទាំងអស់ជ្រាប ហើយនិងចូលមកបន្តកិច្ចដំណើរការសវនាការនូវព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សូមអញ្ជើញលោកមេធាវីការពារក្ដី នួន ជា!

[១១:៥៥:១៧]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំបានយល់ថាល្ងាចនេះ យើងមិនមានសវនាការទេ។ ហើយចុះថ្ងៃស្អែកវិញ លោកប្រធានអង្គជំនុំជម្រះនឹងត្រូវធ្វើអ្វី បាទ ខ្ញុំអត់ទាន់ច្បាស់ ខ្ញុំយល់ថានឹងដាក់ដេញដោលឯកសារចំពោះភាគីដូចជាចប់ហើយ បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ការដាក់ឯកសាររបស់អង្គជំនុំជម្រះចំពោះមុខភាគីនៅឡើយទេ។ ដោយសារការងារបន្ទាប់ទៅទៀតគឺត្រូវធ្វើឡើងចំពោះឯកសារដែលត្រូវដាក់ចំពោះមុខភាគី ជាពិសេសចំពោះជនជាប់ចោទដោយឡែកផ្សេងទៀតដែលអង្គជំនុំជម្រះមិនទាន់បានដាក់នៅឡើយ។ អង្គជំនុំជម្រះនឹងបន្តកិច្ចដំណើរការនីតិវិធីក្នុងការដាក់ឯកសារភស្តុតាងពាក់ព័ន្ធទៅនឹងដែលជនជាប់ចោទផ្សេងទៀត ចំពោះមុខភាគីនៅព្រឹកថ្ងៃស្អែក។ ប្រសិនបើធ្វើទៅមិនចប់ទេ អង្គជំនុំជម្រះនឹងបន្ត ទៅធ្វើនៅថ្ងៃរសៀល នៅរសៀលស្អែកទៀត។

[១១:៥៦:៣៨]

ដោយឡែក ភាគីដែលអង្គជំនុំជម្រះបានជម្រាបជូនដំណឹងរួចហើយថា នៅទីបញ្ចប់នៃកិច្ចដំណើរការសវនាការចំពោះវគ្គមួយ អំពីអង្គហេតុពាក់ព័ន្ធនឹងបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា គឺធ្វើនៅសប្តាហ៍ក្រោយពីរថ្ងៃ ដោយឲ្យមានការសម្រិតសម្រាំងជ្រើសរើសនូវឯកសារភស្តុតាងសំខាន់ៗដើម្បីដាក់ដេញដោលបញ្ចប់ ហើយនិងពីរថ្ងៃទៀត គឺឯកសារពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះគ្រោងធ្វើសវនាការនៅវគ្គទី២ គឺអង្គហេតុពាក់ព័ន្ធទៅនឹងបរិបទនៃរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ និងទំនាក់ទំនងការងារ ដោយបញ្ហាខ្លះ គឺយើងបានបញ្ចូលនូវអង្គហេតុពាក់ព័ន្ធជាមួយនឹងតួនាទីរបស់ជនជាប់ចោទខ្លះទៀត ដែលមានលក្ខណៈពាក់ព័ន្ធផ្ទាល់ទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងការងារ។

បញ្ហានេះអង្គជំនុំជម្រះបានជម្រាបជូនភាគីព្រឹកមិញ ដោយមន្ត្រីច្បាប់ជាន់ខ្ពស់រួចហើយ។ ចំណែកឯការជម្រាបជូនជាផ្លូវការ គឺក្រោយពេលបញ្ចប់សវនាការនេះនៅរសៀលនេះ យើងនឹងចេញជាផ្លូវការជម្រាបជូនដល់ភាគីបន្ថែមទៀតអំពីបញ្ហានេះ។

សូមអញ្ជើញ!

[១១:៥៨:២៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន អ្ហឺ!លោកស្រីមន្ត្រីច្បាប់ជាន់ខ្ពស់បានផ្ញើម៉ែលមួយជូនយើងខ្ញុំ ដើម្បីស្នើអំពីលទ្ធ-ភាពក្នុងការដាក់ឯកសារនៅដើមសប្តាហ៍ក្រោយ។ យើងខ្ញុំបានឆ្លើយតបជាវិជ្ជមានចំពោះឯកសារនេះ ហើយយើងនឹងអាចដាក់ឯកសារបានចាប់ពីថ្ងៃចន្ទទៅ គឺពីព្រោះថាស្អែកយើងមិនអាចដាក់ជូនបានទេ លោកប្រធាន ពីព្រោះខាងយើងខ្ញុំមិនទាន់បានរៀបចំនៅឡើយទេ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់បញ្ជាក់ជូនតុលាការស្របទៅតាមសេចក្តីណែនាំដែលផ្តល់ជូនដោយតុលាការ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានជម្រាបរួចហើយអម្បាញ់មិញថា ថ្ងៃស្អែក គឺអង្គជំនុំជម្រះបន្តដាក់ឯកសារភស្តុតាងចំពោះមុខភាគីពាក់ព័ន្ធទៅនឹងជនជាប់ចោទដទៃទៀត។ ប៉ុន្តែ ប្រសិនបើភាគីណាដែលបានត្រៀមខ្លួនរួចហើយ បើមានបំណងចង់ដាក់នៅក្នុងថ្ងៃស្អែក ប្រសិនជាមានពេលសល់ដែលពីអង្គជំនុំជម្រះក្នុងការបង្ហាញដាក់ឯកសារភស្តុតាងចំពោះមុខភាគីអាចធ្វើបាន តែប្រសិនបើមិនអាចធ្វើបានទេ គឺតាមកាលកំណត់ កាលបរិច្ឆេទដែលអង្គជំនុំជម្រះបានជម្រាបជូនភាគីរួចហើយ គឺធ្វើនៅសប្តាហ៍ក្រោយ ពីរថ្ងៃសម្រាប់ឯកសារបញ្ចប់នូវអង្គហេតុបរិបទប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ហើយនិងពីរថ្ងៃទៀត ឯកសារត្រៀមសម្រាប់ទៅសួរដេញដោលនូវអង្គហេតុបរិបទរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ និងទំនាក់ទំនងការងារដោយបន្ថែមនូវអង្គហេតុខ្លះ ដោយសារវាមានការពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងការងារ។ ជាភាសាខ្មែរ ខ្ញុំគិតថាទំនងជាច្បាស់ហើយ។

[១២:០០:៣០]

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការត្រឹមនេះ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបត្រឡប់ទៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទទាំងបីរូបមកកាន់មកបន្ទប់សវនាការនេះនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១២:០១ នាទី)*